CEN
CAMBODIA EXPRESS NEWS

# ស្នេហ៍អពមង្គល


**និពន្ធដោយ**

**សុទ្ធ ប៉ូលីន**


ប្រលោមលោកផ្អែកចិត្តសាស្ត្រ
ស្នេហ៍អពមង្គល
សុទ្ធ ប៉ូលីន

## សោភ័ណជីវិត គឺគ្រោះថ្នាក់ និងការផ្សងព្រេង

ខ្ញុំនេះជាមនុស្សលង់ខ្លួនជោគជាំទៅក្នុងកាមគុណ ហើយមិនតែ ប៉ុណ្ណោះ ជាមនុស្សស្រេកឃ្លានយ៉ាងសម្បើម នូវការផ្សងព្រេង ។ **ខ្ញុំស្គាល់** ច្រើនណាស់ **ទាំងកូនក្រមុំគេផង ទាំងស្រីសំផឹងទៀត** នៅក្នុងក្រុង បាត់ដំបង ដូចជាមីកំពៅ. មីការ៉ុម. មីកាថា. មីកាថុន. មីក្អួន. មីក្បូត្រ ។ល។

ខ្ញុំចេះតែរៀនប្រឡងជាប់ដែរបើម្ល៉ឹងៗ ។ សព្វថ្ងៃនេះខ្ញុំនៅថ្នាក់វិទ្យាសាស្ត្រ "ស្វូត" ក្នុងវិទ្យាល័យបាត់ដំបង ហើយរៀនបានលេខ ១០ ទៀតផង ។ ឃើញថាផ្នែកកម្លាំងប្រាជ្ញាខ្ញុំអាចទុកចិត្តច្រើនទៅលើសមត្ថភាពរបស់ខ្ញុំ ។ បាក់ឌុបឆ្នាំងនេះ មើលទៅខ្ញុំប្រហែលពួយរបូតទៀតហើយ ។ តែបើនិយាយពីជោគ ជ័យជាមួយស្រីវិញ (Les succe's amoureux). ខ្ញុំមិនបាច់ប្រឡងទេខ្ញុំជាប់សញ្ញាប័ត្រកំពូលតែម្តង ។

នៅក្នុងឱកាសបុណ្យអុំទូកថ្មីៗ នេះ, ខ្ញុំបានឆ្លៀតលែលកទៅលេង ក្រុងភ្នំពេញ ។ ខ្ញុំបាកកុហកម៉ែខ្ញុំថា : "ម៉ែ ! ខ្ញុំចង់ទៅលេងបុណ្យអុំទូកណាស់ គឺបុណ្យទំនៀមទំលាប់ ដែលជាកេរ្តិ៍ដំណែលពីដូនតាយើងមក ។ ម្យ៉ាងទៀតខ្ញុំ ឆ្លៀតទៅទិញសៀវភៅថ្មីៗផងនៅបណ្ណាគារធំៗ ដូចជា បណ្ណាគារអាហុងយូ ឬ អាដួងដួណារីជាដើម" ។ ម៉ែខ្ញុំចាញ់កលមេបោក ក៏បានបន្តិចមួយពាន់រៀលមក ឱ្យខ្ញុំ ... ។

តាមពិតខ្ញុំទៅភ្នំពេញម្តងនេះ គឺដោយមានចិត្តត្រេកត្រអាលចង់ភ្លក្ស ស្រីភ្នំពេញម្តង ... ព្រោះស្រីបាត់ដំបងដូចជាដដែលៗពេកខ្ញុំធុំទៅហើយចង់ទៅ សាកម្ហូបថ្មី. ហើយដោយមានបុណ្យអុំទូកជាទស្សនិយភាពលំអផង ...ការភ្លក្ស ស្រីៗថ្មីនៅភ្នំពេញមិនដឹងសប្បាយយ៉ាងណា ?

ដូច្នេះ . នៅយប់ទីពីរនៃថ្ងៃបុណ្យ ខ្ញុំបានទៅជ្រមុជជ្រមុលងប់ងល់ ឆេះកុដិផ្តាំអង្គរបុរី ជាមួយមេអំបៅជ្រោយ មៀនពីរបីនាក់ ក្មេងៗ ដែលមានសាច់ខ្ចីល្អក់ ល្អកល្អនដូចផ្កាក្រពុំ. តាំងពីព្រលប់ស្រាងៗរហូតដល់ម៉ោង ១២ យប់ ... ។

ខ្ញុំសូមបញ្ជាក់ថា ក្នុងយប់នោះ បើខ្ញុំសង្វាតរកស្រីត្រឹមត្រូវក៏បានដែរ ... ដូចជាកូនក្រមុំគេ ឬប្រពន្ធគេ ... ព្រោះខ្ញុំដឹងថា ស្រីៗល្អៗតែមានពេល បុណ្យប្រចៀតគ្នាម្តងៗ តែងឡើយឈាមខ្លាំងណាស់ ... ដើរទៅប៉ះប្រុសៗ ច្រើនឡើងក្តៅមុខក្តៅមាត់ ។ បើមានថៃដន្យ .. ឬឱកាសហុចឱ្យបន្តិច ។ គឺ ច្បាស់ជាលង់ខ្លួនមួយពេលសិនហើយ ។ ធម្មតាមានបុណ្យទាន ... ប្រុស ! ស្រឡាញ់ស្រីៗ តែទាំងអស់ ... ឱ្យតែស្អាតៗ ... ហើយស្រីៗក៏ស្រឡាញ់ប្រុសៗ តែទាំងអស់អញ្ចឹងដែរ ។

ខ្ញុំឈរញ៉ាំទឹកកកនៅវាលមេរុ ហើយទាក់ទងនឹងកញ្ញាពីរនាក់ក្បែរ នោះ សឹងតែរបូតយកមកបាន ។ ប៉ុន្តែខ្ញុំមកនឹកថា ខ្ញុំខ្វះពេលវេលាខ្លាំងណាស់ ... ហើយការចែចង់ស្រីរបៀបនេះ ... ត្រូវ "ប្រើសេចក្តីផ្តើម " (introduction) ដ៏វែងទៀតផង ។ ម្ល៉ោះហើយខ្ញុំខ្ជិលតស៊ូ ... ក៏ស្វែងទៅ ជ្រោយមៀម ដើម្បីឆាបចូលសាច់រឿង ហើយឆាប់ចប់ ។

នៅជ្រោយមៀម ខ្ញុំបានចំណាយអស់ ៣០០ រៀល ឱ្យពួកមីចោរហិន ហោចអស់ហ្នឹង ។ ខ្ញុំបានពួយយ៉ាងតិចក៏ប្រាំដងដែរ ។ លេងមិនស្រួលទេ អាស្មៀតនេះ , រួចហើយចង់ឆ្អួត ។ សំណាងដែរ ខ្ញុំបានពិសិទ្ធឡូថ្មី ដល់ទៅប្អូន ។ ស្រីរាត្រីអស់នេះមានប្រដាប់ប្រដាវាល្អណាស់ ... មាំមួនណែន , ស្រួលជាងរបស់លោកស្រីខ្លះផង ។ ខ្ញុំភ្លឹកនឹងក្តិតមីមួយនេះ ដែលរាងវាដូចស្លឹកពោធិ៍ មើលពីលើទៅឡើងកោងខុប ដូចក្បាលឡានអាវ៉ុល វ៉ាគ្លេន ។ ខ្ញុំសម្លឹងមើល ភេទនេះឥតឆ្អែកឆ្អន់ ខ្ញុំឥតទុកវាជាស្រីសំផឹងទេ ... ខ្ញុំទុកដូចជាកូនក្រមុំគេ ។

ខ្ញុំចេញពីមហាវិទ្យាល័យ ជ្រោយមៀនមកស្រាប់តែភ្លើពេញបន្ទុកតែម្តង ។ គួរដែរ ! ថីក៏មិនធេងធោងបើពីក្បាលល្ងាចខ្ញុំដើរប្រចៀតស្រីក្រមុំ ប៉ះ ដោះវក់វីដូចជ្រូកពុលបន្ទាប់មកខ្ញុំយោកយាក់ស្នេហា នៅក្នុងអាផ្ទះអណ្តែត ទឹកអស់ជាច្រើនម៉ោង ។ ពេលរលកបោកបក់គ្រាំៗម្តង ផ្ទះនោះញាក់អង់ខុងៗ ចំណែកខ្ញុំនឹងគូនៃមនិត្យត្រូវក្រឡេងវង្វេងមិនដឹងដល់ឋានណា ។

ខ្ញុំជិះអាសូឡេចស្ទើរពុំកើត ព្រោះវាវិលខ្លាំងពេក ។ នឹកសព្វៗទៅគួរឱ្យច្រណែន ដក់ពួកមីស្រីផ្កាមាសទាំងនោះ ណាស់ព្រោះវាគ្មានកើតអីបន្តិចសោះ ។ ចង់វាត្រូវថ្នាំអាណើបសង់កាទ័រប្រាំងខ្សៀក៏ដោយ ក៏វាគ្មានវិលគ្មានញ្ញោចបន្តិចដែរ ។ នៅដៃលឯងឯណេះខំឱបវាឱ្យស្វិត ឯងខំញាក់សឹងតែដាច់ត្រសៃ យឹងវានោះអាល័យតែច្រៀងព្រងើយ វាបើកវិទ្យុជាតិ ស្តាប់ចម្រៀងអាយ៉ៃយ៉ាងសប្បាយចិត្តទៅវិញ ។ ដោយពេលនោះ ស្រីចម្រៀងដៃគូនាយសាលូត បានច្រៀងថ្លែងថា នាងសុខចិត្តឱ្យគេ "ចូលម្តងទាំងបី" នាយសាលូតក៏តបថា ចូលតាមណា ? មិនខ្លាចទង្គិចក្បាលគ្នាទេឬអ្វី ? ស្រាប់តែរំពេចភ្លាមនោះ មីខ្ញុំ វាដាលវាលក្តិតខ្វាំផង និយាយផង : "បងឯងរុញឱ្យវាចូលទៅបីទៅមើលខ្ញុំអត់ខ្លាចទេ ! "។ មីចោរមេអំបៅហ្នឹងចំតែម្តង ឱមីកាធុំថេត ! (មីមួយហ្នុង ឈ្មោះវាមីកាធុំថេក) លុះដល់ពេលនាយសាលូតបានថ្លែងយ៉ាងឱឡារិកថា គាត់ដាក់ម៉ាឆែតបានម៉ាត្រឡោក មីខ្ញុំក៏បង្អាប់ខ្ញុំថា បងឯងក៏អន់ជាងគេខ្លាំង ម្ល៉េះគេក្អួតម៉ាឆាច់បានម៉ាត្រឡោក ចំណែកបងឯងវិញ ម៉ាច្រូចមិនបានកន្លះពែងផង ។

ខ្ញុំធ្ងន់ខ្លួនជាខ្លាំងជិះអា Solex ឃ្លេងឃ្លោងដូចជាជិះទូក ។ ខ្ញុំត្រូវឆ្លងទៅគេងសំណាក់នៅផ្ទះមិត្តខ្ញុំម្នាក់ឯជ្រោយចង្វារ ។ ពេលដែលខ្ញុំបើកទៅ ចក្រយានយន្តនេះឡើងស្ពានដ៏ខ្ពស់សន្លឹមខ្ញុំក្រឡេកមៀងមើលទៅនាឡិការ ដែលប្រកបដោយទ្រនិចភ្លឺផ្លេកឃើញម៉ោង ១ ខ្វះ ដប់ប្រាំនាទី ។

ឡើងមកដល់ពាក់កណ្តាលស្ពាន ។ ខ្ញុំព្ធខ្យល់ថ្ងូរហ៊ូៗគួរឱ្យព្រឺ ។ ខ្ញុំក៏ដាច់ចិត្តដាក់ចន្ទល់ Solex ។ ក្បែរបង្កាន់ដៃស្ពានដើម្បីក្រេបជញ្ជក់យកភាពស្ងប់ស្ងាត់និងអាកាសត្រជាក់បរិសុទ្ធនៃទន្លេសាបបានបន្តិច ។

ខ្ញុំដកស្រូបពេញសួតនូវវាយោរំភើយ ដែលជះមកលើផ្ទៃមុខខ្ញុំ ដែលប្រឡែងលេងជាមួយនឹងសក់ខ្ញុំ បណ្តាលឱ្យសរសៃវាផាយផាត់រសាត់រក់រឺចុះឡើង ។ ដួងវិញ្ញាណខ្ញុំពេលនោះក៏ដូច្នោះដែរ ត្រូវខ្យល់ជំនោរកញ្ឆក់យកទៅជ្រលក់ក្នុងការសញ្ជប់សញ្ជឹងវែងឆ្ងាយមួយ ។ ខ្ញុំនឹកមមៃ សុំភេទគិតទៅអនាគតនៃជីវិតខ្ញុំ ។ ខ្ញុំសម្លឹងឃើញថា ខ្ញុំនេះមិនមែនត្រឹមតែជាមនុស្សល្មោភកាមតណ្ហាប៉ុន្នោះទេ ខ្ញុំជាមនុស្សដែលស្រេកឃ្លាននូវគ្រោះថ្នាក់ និងការផ្សងព្រេង គ្រប់បែបយ៉ាងទៀតផង ឬក៏ថាការផ្សងព្រេងនោះជាតណ្ហាមួយទៀត !! ម្ល៉ោះហើយវត្ថុណាដែលគ្មានបង្ហាញ គ្រោះថ្នាក់ចំពោះខ្ញុំទេ ខ្ញុំគ្មានត្រេកត្រអាលសោះឡើយ ។ ទុកជាស្រីញី គ្រឿងបំរើកាមគុណក៏ដោយក៏គ្មានរសជាតិដែរ បើសិនជាខ្ញុំមិនពិបាក ដើរកាត់ស្វែងរកវាតាមផ្លូវស្ងាត់ងងឹតឈឹង តាមច្រកល្ហក ដែលមានលាក់បង្កប់នូវគ្រឿងគួរខ្លាចគ្រឿងស្មោកគ្រោក និងគ្រោះថ្នាក់ក្រោយខ្នងផ្សេងៗ ។ ដូច្នេះសោភ័ណនៃជីវិត គឺស្ថិតនៅលើការប្លែក និងគ្រោះថ្នាក់តែម្តង គឺមិនមែននៅលើការស្រណុកកាយស្រណុកចិត្ត គ្មានភ័យភិត ឬក៏នៅលើគំនរទ្រព្យសម្បត្តិ ដែលជាគ្រឿងបញ្ឆោតដែលធ្វើឱ្យចិត្តមនុស្សកំសាករួញរាខ្លាចរអារធ្លាក់ខ្លួនទៅជាកំអែលចុះញ៉មចំពោះធម្មជាតិ ។ ចាំមើលជាប់ បាក់ឌុបរួចហើយខ្ញុំនឹង តាំងខ្លួនជាអ្នកដើរផ្សង ព្រេងអន្តរជាតិម្នាក់ធ្វើជាគូលី (អា matelot) កប៉ាល់ក៏បានធ្វើជា (reporter) អ្នកឈ្លបយកការណ៍ឱ្យសារពតិមានក្នុងប្រទេស ដែលមានកើតចម្បាំងក៏បាន ។ ខ្ញុំចង់ស្គាល់ណាស់នូវការលំបាកការហត់នឿយ និងការកម្សត់ ។ ខ្ញុំមិនមែនស្រេកឃ្លានចង់ប្រហារ ជីវិតគេនោះឡើយ ប៉ុន្តែខ្ញុំចង់រត់រងគ្រាប់បែកជាមួយគេដែរ ខ្ញុំចង់ហាមាត់ សើចចំអកចំពោះមុខគ្រាប់កាំភ្លើង ។ គ្រោះថ្នាក់ជាស្នេហ៍ជាសោភ័ណនៃបេះដូងខ្ញុំពិតៗ ។ នៅក្រោយមេឃនេះ ខ្ញុំស្ញើចកោតសរសើរ ជាងគេតែពពួកមនុស្ស ដែលរកស៊ីបើករថយន្តប្រណាំង បើកកប៉ាល់ហោះក្រឡាប់ផ្កាប់ផ្ងារ, លោតឆ័ត្រយោង, ដើរលើខ្សែពួរជិះម៉ូតូឡើងជញ្ជាំង ... ប្រតិបត្តិការវាយ កំទេចកម្លាំងទ័ព រុករានរបស់ពួកអាចក្រពត្តិឈ្លានពាន ។ ល ។ ភ្លាត់តែមួយចំអាមធ្លាក់បត់ក ប្រកាច់តែសាក ដើរខុសផ្លូវតែមួយជំហាន ស៊ីគ្រាប់រំសេវ ពេញពោះដូច្នេះ ទើបសប្បាយបាន ។ រស់រងគ្រោះថ្នាក់រស់នៅលើច្រាំងមច្ចុរាជទើបគេហៅថារស់ពិតៗ ។ បើយើងរស់សម្រាប់តែជញ្ជក់សេចក្តីសុខទេ **គឺ យើង ស្លាប់មុនខាប់** ។ ពាក្យថា **សុខ** ហើយ និង **សប្បាយ** នេះ មិនចុះ សម្រុងគ្នាសោះឡើយ ។ បើយើងចង់សប្បាយគឺមានន័យថា យើងត្រូវការជីវិតជ្រួលច្របល់ ។ ចំណែកសេចក្តីសុខវិញ គឺជាភាពស្លាប់ ។ បើយើងស្រឡាញ់ សេចក្តីសុខណាស់យើងត្រូវដេកស្ងៀមស៊ីចុកមួយកន្លែងកុំកម្រើក ។ សប្បាយ គឺអត់សុខ សុខប្រាកដជាអត់សប្បាយ ។

ខ្ញុំនឹកថា ដរាបណាជីវិតខ្ញុំអស់កាលលំបាកហើយ .. ពេលនោះជីវិតខ្ញុំ អស់តម្លៃហើយ ... មិនគួរចង់ទុកតទៅទៀតទេ ។ បើគេឱ្យខ្ញុំទៅនៅឋានសួគ៌ តែកន្លះថ្ងៃ ខ្ញុំស្រែកទ្រហោយំទាល់តែបែកទ្រូងស្លាប់ហើយ ។ ដេកលើគំនរមាស, គំនរប្រាក់, គំនរពេជ្រមិនដឹងជាចាយទិញក្រមុំអី, គ្មានភ័យខ្លាច គ្មានព្រួយបារម្ភសោះមានតែទេពអប្សរ បវរកញ្ញាបំរើឆ្វេង ស្តាំ។ **ខ្ញុំសុខចិត្តខ្ទេះភ្លិតឱ្យចេញឈាមមកដេកពេទ្យរុស្ស៊ីទិញប្រសើរជាង ២**

ឧត្តមគតិដ៏ធំបំផុតរបស់ខ្ញុំក្នុងជាតិនេះ គឺត្រូវទាត់សុភមង្គលចោល ខ្ញុំត្រូវរកឱកាសឆ្លៀតយ៉ាងម៉េចឱ្យបានស្លាប់ពីក្មេង គឺស្លាប់ក្នុងការប្រឡែងលេង ជាមួយគ្រោះថ្នាក់ ។ ខ្ញុំខ្លាចបំផុត ខ្លាចតែរស់ដល់ចាស់ប៉ុណ្ណោះ ។ ខ្ញុំសូមស្រែក ស្របជាមួយលោក Mermoz "Jean Mermoz (pilote de ligne et d'essai) mort en 1936 . C'est un des héros les plus de l'aviation francaise." ថា : L'accident c'est de crever dans un lit (គ្រោះថ្នាក់ គឺការស្លាប់នៅលើគ្រែ) ។ ចំណែករឿងលុយកាក់វិញ ក្នុងជាតិនេះខ្ញុំសុំរកវាតែ "ម៉ារស់១ "ចុះ, បើទុកជាខ្ញុំមានសំណាងបានរៀនសូត្រជាប់លីសង់ដុកទ័រ ឬ Agrégéក៏ដោយ ។ តើឱ្យខ្ញុំរកវាលើសម៉ារស់មកធ្វើអ្វី ?! ខ្ញុំសង្កេតឃើញមិត្ត ខ្ញុំឯទៀតជាច្រើន ដែលចង់រកលុយដើម្បីមាន គេចង់រកលុយដើម្បីអំនួត គេចង់រកលុយដើម្បីលុយ ។ មិត្តខ្ញុំគេខំរៀន គេខំឱបក្រសោបចំណេះវិជ្ជា គេខំប្រមូលឧត្តមគតិ គឺសម្រាប់តែបម្រើលុយ ។ ឱ ! អាលុយ ! អាមាស ! អា ពេជ្រ ! វត្ថុស្អុយជាងគម្រង់ឆ្កែ កើតមកសំរាប់តែសំអុយសតិសម្បជញ្ញៈល្អ និងបេះដូងបរិសុទ្ធតែប៉ុណ្ណោះ ។ ឱ ! មិត្តខ្ញុំអើយសូមមិត្តនៅប្រដែងគ្នាចុះដូចត្រីឆ្លៀត ឬត្រីចង្វាប្រដែងចឹកដុំលាមក ។ ខ្ញុំសូមលាសិនហើយ សេចក្តីសុខនិយម សុភមង្គលនិយមបុណ្យសក្តិនិយម ! ទ្រព្យសម្បត្តិនិយម ហូ ! ហូ ! ហូ ! Sayonara ! good bye ! ខ្ញុំសូមលា ដោយខ្ពើមរអើម ។ ...

**នាយតួកំបុត**

***សម្លេងក្អកខេះៗខុចៗ*** យ៉ាងស្ងួតផុះនៅក្បែរខ្លួនខ្ញុំ ញ៉ាំងឱ្យ វិញ្ញាណខ្ញុំរបូតចេញពីភពនៃទ្រឹស្តី ។ ខ្ញុំងាកក្រឡេករកមើលម្ចាស់សម្លេងយ៉ាងប្រញាប់ ខ្ញុំឃើញស្រមោលមនុស្សម្នាក់ស្កុង១ ទ្រោបលើបង្កាន់ដៃស្ពានខាងស្តាំខ្លួនខ្ញុំ កំពុងប្រឹងក្អកឡើងគ្រវៀងខ្លួន ។ សម្លេងនេះ ហាក់ដូចជាបង្ហាញនូវភាព រលួយស្អុយពន់ប្រមាណ ខ្ញុំស្រៀវស្រាញស្ទើរទ្រាំពុំបាន ។ ខ្ញុំខំប្រឹងអត់ជំនួស ហើយខាំថ្គាមស្ទើរបែក ។ មិត្តយើងនៅតែបន្តចម្រៀងអប្រិយនេះ អស់មួយស្របក់ធំ ។

-សូមទោស ( សម្លេងនេះបង្អើរមកចំពោះខ្ញុំ ) ។

-បាទ ! មិនអីទេលោក ( ខ្ញុំឆ្លើយតប) ។

ពេលនោះ ហ្វូងតារាទាំងឡាយ រះព្រោងព្រាតលើផ្ទៃមេឃ ហើយផ្សាយពន្លឺមកព្រិច១ ។ ដោយកាខំប្រឹងសម្លឹងស្ទើរលៀនគ្រាប់ភ្នែក ខ្ញុំសង្កេត ឃើញថា ជននោះពាក់វែនតាពណ៌ ហើយដៃកាន់ដបមួយផង ។

យើងទាំងពីរស្ថិតក្នុងការស្ងាត់ស្ងៀមយ៉ាងយូរ ។ ភាពនេះធ្វើឱ្យខ្ញុំ រសាប់រសល់ពេញទំហឹង ស្ទើរទប់ខ្លួនមិននឹង ។ ខ្ញុំហៀបដើរចេញពីទីនោះ ទៅ ឈរនៅកន្លែងផ្សេងទៅហើយ ប៉ុន្តែខ្ញុំមកនឹកគិតថាកាយវិការនេះ ដូចជារហ័សរហួស ដូចជាកំបុតកំបុយខ្លាំងពេក ។ ដោយចង់បន្ទប់សេចក្តីសុខារីកក្នុងចិត្ត ខ្ញុំក៏ទាញបារីមួយមកជក់ ។ ខ្ញុំគូសឈើគូសលាន់ក្រាក ដុំភ្លើងរីកប៉ោងឆួល ឡើងទម្លុះស្បៃងងឹតបានប្រហែលដប់ម៉ែត្រត្រីគុណ ។ ក្នុងនាទីនោះខ្ញុំឆ្លៀត ក្រឡេកមើលទៅជនដែលឈរក្បែរខ្លួនខ្ញុំ១ព្រឺខ្លួនខ្វាកមួយរំពេច ។ ឱ ! មុននេះបានចំអស្ចារ្យ ហើមស្ពុលស្ទើរប្រេះធ្លាយមានពណ៌ខៀវដូចខ្ទុះខួរអណ្តែង ។ មុខនេះមានភាពដូចជាមុខខ្មោច អសុរកាយ ដែលគេចំណាំ

ស្រមៃឃើញនៅ ពេលយល់សប្តិអាក្រក់ ។ B r r r r ! ! ! ខ្ញុំត្រជាក់ឆ្អឹងខ្នងស្ពួតជើងធ្មេញ ។ ខ្ញុំ រកសង្កេតភិនភាគអ្វីទៀតពុំកើត ព្រោះអណ្តាតភ្លើងឈើគូស ត្រូវស្នៀងធីតត្របាក់លេបទៅបាត់វិញសូន្យ ។ ខ្ញុំនៅឈរទ្រឹងស្មារតី មិនហ៊ានកម្រើល ។ ខ្ញុំ ទុកជននោះដូចជាពស់វែកមួយ ដែលសម្ងំទៅប្រគាបឈើលើក្បាលខ្ញុំ ។ ខ្ញុំ ឧបមាថា ខ្ញុំកម្រើកខ្លួនតែបន្តិចពស់នោះនឹងហក់មកចឹកខ្ញុំមិនខាន ។ ម្ល៉ោះហើយ បរិយាកាសរវាងយើងទាំងពីរមានសភាពកាន់តែធ្ងន់តឹងរ៉ឹងខ្លាំងឡើង១ ។

រំពេចនោះសម្លេងក្អកខេះខុង១ ក៏ចាប់ផ្តើមឡើងម្តងទៀតយ៉ាងរញ្ជួយហើយយ៉ាងយូរ ។ សម្លេងក្អករសាត់ផ្ទួន១គ្នាញាប់រន្ថើនធ្វើឱ្យគាត់នោះ រកកល់ដកដង្ហើមសឹងពុំបាន ។ ខ្ញុំប្រថុយដើរចាកចេញយ៉ាងសន្សឹម១ ។ ខ្ញុំបោះជំហានដោយលំបាកបំផុត ស្ទើរតែភ្លាត់ជើងដួលណាមួយចេះតែនឹកថា ខ្លួនឯងនេះជាមនុស្សកំសាក ណាមួយចេះតែរអើលខ្នង ដោយខ្លាចបុរសនោះមកច្របាច់កពីក្រោយ ។

ក្លីស ! ក្លីស ! ក្លីស ! ក្លីស១! សម្លេងស្បែកជើងឈើរត់លើថ្មបន្លឺ ឡើងគួរឱ្យរន្ធត់ពីក្រោយខ្ញុំ, ខ្ញុំប្រហោងពោះធ្លុង ។

បុរសនេះរត់តាមខ្ញុំទៅតើ ! យ៉ាងម៉េចអញ្ចោះ ? ខ្ញុំឈប់ស្ងៀមរង់ចាំ មើលព្រឹត្តិការណ៍ ចំណែកបេះដូងខ្ញុំលាន់រណ្តំស្ទើរបែក ។

-សូមទោសលោក ! សូមលោកឈប់ ... ឈប់បន្តិចសិន ( បុរសនោះ ពោលជាប់១យ៉ាងត្រដាបត្រដួសហាក់ដូចជាសុំអង្វរ)

-លោកដឹងទេ ! ខ្ញុំ ... ខ្ញុំ មានរឿងដំបៅទ្រូងធំណាស់ ... ខ្ញុំភៀសខ្លួន រត់គេចចេញពីសង្គមមនុស្ស ... ហ៎ ! ហ៊ឺ ...!

មាណពនៅស្ងៀមមួយស្របក់ទើបបន្ត :

-គឺថា .. គឺ ... គឺថា ខ្ញុំរកមធ្យោបាយរស់ជាមួយគេឯងពុំកើត ។ ពេលនេះខ្ញុំឃើញលោកជាមនុស្សចម្លែកម្នាក់ ដែលមកឈរតែឯងលើស្ពាន ម៉ោងមួយយប់ ខ្ញុំក៏មកដុះចិត្តចង់សាសងសម្តីជាមួយលោកខ្លះ ។

-ឱ បាទ ... លោក ! មានអី ខ្ញុំចូលចិត្តណាស់នូវការប្តូរមតិគ្នាដូច្នេះ ។

តាមពិតខ្ញុំសប្បាយចិត្តបន្តិចមែន ! សប្បាយផងភ័យផង ។ គឺជាការធម្មតា ជីវិតមនុស្សតែងតែមានលំនាំដូច្នេះឯង ។ បើយើងខ្លាចខ្មោចណាស់ មានអាចិត្តចង្រៃមួយ ចង់តែនាំយើងឱ្យដើរទៅជិតប៉ាឆាខ្មោចចង់តែឱ្យអា ខ្មោចនោះវាលេចចេញមកដើម្បី មកលៀនអណ្តាតឬទម្លាក់សក់ឱ្យយើងឃើញ ។

ម្យ៉ាងទៀត ខ្ញុំនេះជាអ្នកចំណូលខាងស្រាវជ្រាវផ្លូវចិត្តផង ។ រឿង ដំបៅទ្រូង រឿងពុករលួយ ឬផ្លូវក្នុងបេះដូង តែងធ្វើឱ្យខ្ញុំស្រើបចង់ដឹងជាទីបំផុត ។ កម្លាំងនៃការចង់ដឹងនេះ ខ្លាំងដូចជាការស្រឡាញ់ស្រី១ដូច្នោះដែរ ។ មុននឹងក្លាយខ្លួនទៅជាអ្នកផ្សងព្រេងអន្តរជាតិ ខ្ញុំត្រូវមានការពិសោធន៍នៃកន្លុក កន្លៀតចិត្តមនុស្សឱ្យបានគ្រប់គ្រាន់ ។

ប៉ុន្តែយ៉ាងណាក៏ដោយ ពេលនេះចៀសព្រឺឆ្អឹងខ្នងមិនរួចសោះ ។ សម្លេងបុរសនោះស្អក១លាន់ឡើងតទៅទៀតដូចសម្លេងព្រាយក្នុងរាត្រីស្ងាត់ ។

-ខ្ញុំខាននិយាយស្តីយូរខែ យូរឆ្នាំហើយលោក ។ ខ្ញុំមានអំណរកអ្វី ប្រៀបគ្មាន ដោយបានឱកាសគ្រលាស់អណ្តាតខ្លះក្នុងវេលានេះ ។ ឱ ! ខ្ញុំវេទ នាសម្បើមណាស់ ដែលខ្ញុំលាក់រឿងពុករលួយទាំងប៉ុន្មាន បង្កប់ក្នុងដើមទ្រូង ដូច្នេះ ... យូរ ! ទៅស្ទះខ្យល់រកកល់នឹងស្លាប់ដង្ហើម ។ យប់នេះមុននឹងលាជីវិតទៅស្កាត់ជួបមីសំធឹងរបស់ខ្ញុំ ខ្ញុំនិងបានសប្បាយ "និយាយមួយភ្លែតដែរ" ។

ពាក្យប៉ុន្មានម៉ាត់ចុងក្រោយនេះ គេសង្កត់មុត១អស្ចារ្យ ។ ដោយ រំភើបខ្លាំងពេក ខ្ញុំពុំដឹងជាគេចង់និយាយរឿងអ្វីផង ។

-យីលោក ! ខ្ញុំឆ្ងល់ណាស់ មនុស្សយើងក៏ខ្លាចងាប់ខ្លាំងម្ល៉េះ រស់នៅក៏មិនដឹងនៅធ្វើអ្វីដែរ ។.. ឥតប្រយោជន៍ ប៉ុន្តែដល់ពេលងាប់ភ័យស្លន់ស្លោជាង សត្វឆ្កែ ឬសត្វជ្រូកទៅទៀត ... ហាថ៍ ! ហ៎ ! ហ៎ ! ហ៎ ! ( បុរសយើងសើចក្អាកក្អាយ ) ។

-ចម្លែកណាស់លោក ចម្លែកណាស់ជីវិតមនុស្សយើងមិនចេះអស់ សោះរឿងប្លែក ។

បុរសក៏បន្តសំណើចទៅទៀត យ៉ាងខ្ទរខ្ទារ ប៉ុន្តែបានមួយសន្ទុះសម្លេងក្អកខុង១ ក៏ផ្ទុះជំនួសវិញម្តងលែងចង់ព្រមរបូត ។ ស្ងៀមយូរណាស់... ទើបគេ ចាប់ពោលមួយ១ ដូចមនុស្សទើបនឹងស្វាងសុរា :

-យើងកើតមកម្ដេចក៏ចាំបាច់ដឹងខ្លួនធ្វើអ្វី ? ម្ដេចចាំបាច់មានប្រាជ្ញាធ្វើអ្វី .? បើដូចសត្វវិញមិនប្រសើរជាងឬ ? ព្រោះការដឹងរបស់យើង គឺគ្រាន់ តែដឹងថា ជីវិតគ្មានអ្វីសំខាន់តែប៉ុណ្ណោះ ...ទទេ !! ការដឹងរបស់យើងគឺគ្រាន់ តែដឹងថា មនុស្សថោកទាបអាក្រក់ក្រខ្វក់ដូចសត្វ ឬក៏ពុករលួយជាងសត្វទៅទៀត ចំណែកអាសត្វដែលឥតដឹងថាខ្លួនវាជាសត្វ មិនគ្រាន់បើជាងសត្វមនុស្ស ទេឬ ? ... លោកជួយមើលព្រហ្មលិខិត វាបន្ថោកមនុស្សដល់កម្រិតហើយ ។ កើតមកចាំបាច់ឱ្យគ្នាមានអសុភ .. មានពោះវៀន ... ក្រចក ...ធ្មេញ ... ប្រហោងច្រមុះ ប្រហោងក្ដិត អាររឆេញរឆុញ រតេយរតាយគ្រប់សព្វយ៉ាង ។ ម្ល៉ោះហើយបញ្ញាវិចារណញ្ញាណរបស់យើង គឺសម្រាប់តែឆ្លុះប្រាប់យើងថាយើង នេះជាកំអែលពុករលួយរបស់ធម្មជាតិប៉ុណ្ណោះ ។

គេឈប់និយាយមួយស្របក់ , ឆ្លៀតឱកាសនោះ ខ្ញុំជូនបារីមួយទៅ មិត្តយើង គេព្រមទទួលយកដោយគ្មានប្រកែករឹងរូស ។ ភ្លើងឈើគូស កំរោល រីកឆួលឡើងម្ដងទៀត បានមួយកញ្ចុំ ភ្នែកខ្ញុំឆ្លៀតប្រញាប់ក្រឡេកមើលមុខអសុរកាយនេះម្ដងទៀត ។ ហ៊ូ ! ហ៊ូ ! ព្រលឹងខ្ញុំស្ទើររលោះបាត់ ។ លោកអើយ ចក្ខុគាត់ហ្នឹងទាំងគូល្បៀនផ្លែល ក្រហមដូចឈាម នៅក្រោយកញ្ចក់កែវវ៉ែនតា ។ ភ្នែកក្រឡោតនេះផ្ដោតមកលើមុខខ្ញុំ ហាក់ដូចចង់ហែកហួរយកខួរខ្ញុំជញ្ជក់ ស៊ីតែម្ដង ។

-មិនត្រឹមតែប៉ុណ្ណឹង (នាយអសុរកាយអធិប្បាយបន្ត) អាប្រដាប់ ប្រដាររឆេញរឆុញរបស់យើង ផុយអីក៏ផុយម្ល៉េះទេ ។ មេរោគក៏អាចស៊ីវាដាច់ របេះរបុញ ... ផ្លែកាំបិតក៏អាចកាត់វាដាច់ត្រឡាញឆុញ ។ លោកសាកស្លឹក ត្រចៀកលោកជាមួយកាំបិតកោរម្ដងមើល ដាច់ស្រួលស្មើត្រឹមល្អណាស់ ដូចស្លឹកត្រចៀកជ្រូកអញ្ចឹងដែរ ! ... ហើយបើដាច់បាត់ប្រដាប់មួយដុំទៅមនុស្ស យើងពិបាករស់នៅជាទីបំផុតហើយ ... លែងស្គាល់ខ្លួនឯងថាជាស្អី ឬក៏នៅនឹកច្រឡំថា ឥវ៉ាន់ដែលបាត់ទៅហើយនោះ នៅនឹងកន្លែងដដែលវិញ, ប៉ុន្តែដល់ស្ទាបទៅមិនឃើញ តាំងកើតទុក្ខ ... (អសុរកាយស្រាប់តែស្រែកទ្រហោខ្លាំង )រស់នៅពុំកើតទេវេទនាខ្លាំងណាស់ !!! គេឯទៀតគេមានគ្រប់គ្រាន់ឯងឯ ណេះខ្វះមួយដុំ ។ ហើយក្នុងជីវិតមនុស្សយើង តើឱ្យយើងចៀសម្ដេចបានអាគ្រោះថ្នាក់អញ្ចឹង១ ។ ខ្សែជីវិតមានលំនាំដូចយល់សប្ដិពោរពេញទៅដោយការផ្សងព្រេងខ្សៀវខ្សារគ្រប់យ៉ាង ។ តើធ្វើម្ដេចឱ្យយើងចៀសវាសនាអាក្រក់បាន បើយើងសម្បូណ៌ទៅដោយកាំបិតស្នៀត កាំបិតកោរ, កន្ត្រៃ, កាំភ្លើង អាបៃ យ៉ូណែត ,, កាណុង, គ្រាប់បែក, កប៉ាល់ហោះ, រទេះតង់, ឡាន, ម៉ូតូ, កង់ ។ ល ។ អារបស់អស់ទាំងនេះ វាជ្រួលច្របល់ចូលគ្នា ហើយថ្ងៃណាមួយវាគង់តែ ឆ្វតឆ្កួតយកអារឆុញយើងអស់មួយដុម ចូរចាំថាថ្ងៃនោះជាថ្ងៃអង្សារបស់យើង ហើយ ។

-ហ៉ះ ! ហ៉ាស ! ហាយ (បុរសសើចហ៊ោកកញ្ច្រៀវដូចមនុស្សឆ្កួត) អារំបល់យក៏ អាកូនមីចោរ ! អាអន្តរធាន ឯងចាំមើលតែអញងាប់ទៅ អញ ឡើងទៅធាក់ពួកឯងឱ្យធ្លាក់ទៅក្នុងឋាននរកវិញទាំងអសល់ ។ អសុភចម្លែក ងាកមក ហើយបែរនិយាយថ្នមៗថា :

-អ្ហុះ ! សូមអត់ទោស, ខ្ញុំទេវនាណាស់ទើបស្រែកដូច្នេះ ។ ខ្ញុំដឹងថា វាគ្មានព្រហ្មលិខិត, វាគ្មានអាទិទេពក្រមរស្រែងក្ដិតអីទេ ប៉ុន្តែខ្ញុំស្រែកដង្ហោយ ធូរទ្រូងតែប៉ុណ្ណោះ ព្រោះអីលោកដឹងទេ ? ព្រោះអី ? ព្រោះអី ?

ជនអភ័ព្វក៏និយាយសារភាពខ្សាវៗនូវប្រយោគខ្លះ ដែលធ្វើឱ្យខួរខ្ញុំ រញ្ជួយព្យុហ៍ពុះដូចទឹកភ្នំភ្លើង ។ ម្ចាស់ថ្លៃអើយ ! មើលចុះតាំងពីកើតមក ខ្ញុំ មិនដែកព្ទរឿងអីអពមង្គលដល់ប៉ុណ្ណោះទេ ។ សក់ខ្ញុំបះក្រញាងដោយក្ដីរន្ធត់ តក់ស្លុត ។

-ខ្ញុំដាច់ក្ត ... បាត់ទៅហើយ, ឥឡូវនេះខ្ញុំឥតមានលិង្គទេ នៅសល់តែ គល់បន្តិច ដូចគល់ធាងល្ហុង សំរាប់តែបាញ់នោមឆែត១ ។

ជននោះលើកស្រាអកម្ដង ហើយបឺតផ្សែងម្ដង ភ្លើងបារីគេរីកមួយដុំ ប៉ុនរងើកជើងក្រាន ។ បុរសទ្រោបខ្លួនទៅលើបង្កាន់ដៃស្ពានដោយអស់សង្ឃឹមជាខ្លាំង ។ សម្លេងគេក៏រសាត់ចេញមកល្ងើយៗហាក់ដូចជា ឧទានឡើងសម្រាប់ ខ្លួនឯងដូច្នោះ ដើម្បីបរិយាយ "រឿងជ្រោះជីវិតរបស់គេ " ។

**ខ្ញុំឈ្មោះ ភុយ ពីជិត** កូនមហាសេដ្ឋីដ៏ស្ដុកស្ដម្ភអស្ចារ្យម្នាក់នៅ ទីក្រុងភ្នំពេញឪពុកខ្ញុំមានណាស់ ! ណាស់ ... លុយហូរចូលមើលមិនទាន់លុយ គាត់ច្រើនពេកទាល់តែគាត់រាប់មិនអស់, ទាល់តែក្រជាង អ្នកក្រទៅទៀត ។ គាត់ជាថៅកែរោងចក្រផង, ថៅកែឡាន

ផង, ថៅកែសាំងផង, ថៅកែសណ្ឋាគារផង, ថៅកែចំការម្រេចផង ... កន្លែងស្អី ក៏គាត់ថៅកែដែរ ។ គ្រាន់តែខ្ញុំជា កូនគាត់សោះចាយលុយទាល់តែទ្រលាន់ទៅហើយ, ឃើញលុយទៅជាឧបមាថា ក្រដាសកាសែតទៅវិញ ។ ហើយគាត់ចេះតែបុកលុយឱ្យខ្ញុំចាយហើយ ... ភ្លែត១មួយម៉ឺន .. ភ្លែត១មួយម៉ឺន គាត់រុញឱ្យខ្ញុំចាយទាល់តែខ្ញុំធុញដល់កម្រិត ។ រហូតដល់ការចាយវាយរបស់ខ្ញុំគ្មានរបៀប ... មានថ្ងៃមួយនៅពេលរសៀល បន្តិចមិនដឹងជាម៉ោងប៉ុន្មានហើយទេ ខ្ញុំអផ្សុកពេកក៏ក្រោកពីគ្រែ បើកទូយក ខោ អាវមកស្លៀកពាក់ និងទាញសោររថយន្តឆ្វៃលក្រុងភ្នំពេញបានមួយជុំ ក៏នឹកឃើញចង់ទៅក្រុងកែបភ្លាម ខ្ញុំក៏បានដូរចិត្តបើករថយន្តសំដៅតាមផ្លូវជាតិ លេខ ៣ មួយរយៈពេលកន្លងទៅ ពេលដែលរថយន្តខ្ញុំជិតដល់ក្រុងកែបទៅ ហើយជួនពេលនោះ មេឃក៏ចាប់ផ្តើមងងឹតខ្លាំងឡើង១ឯខ្យល់បក់បោកក៏បានធ្វើឱ្យធូលីដីហុយឡើងងងឹត ជាហេតុធ្វើឱ្យខ្ញុំសឹងតែបញ្ឈប់រថយន្តទៅមុខទៀតពុំរួច ពេលនោះខ្ញុំបានឃើញស្ត្រីម្នាក់រត់យ៉ាងត្រហេបត្រហប មកពាំងពី មុខរថយន្តខ្ញុំធ្វើឱ្យខ្ញុំភាំងស្មារតីយ៉ាងខ្លាំងនូវហេតុការនេះ ។

បន្តិចក្រោយមក ស្ត្រីអម្បាញ់មិញនេះ ក៏រត់តម្រង់មកទ្វារឡានខ្ញុំ ។ ហេតុការណ៍ទាំងនេះមានសភាពជាក់ស្តែងជាទីបំផុត ។

-"សូមលោក ...សូមលោក ... "

សម្លេងនេះ បានមកដាស់សតិខ្ញុំ ឱ្យចេញផុងពីការភ័ន្តភាំង ដែលបណ្តាលមកពីការឃើញសុដន់ទាំងគូមូល ក្បុំចំអើតខ្លួនតម្រង់មករកខ្ញុំ ។

-... "សូមលោក ... ជួយខ្ញុំផង (ស្ត្រីនោះពោលឡើងទៀត )ខ្ញុំត្រូវ ពួកអាប្រុស១ខូចពីរនាក់មករំលោភលើរូបខ្ញុំ ... ពួកវាបញ្ឈប់ឡានខ្ញុំដោយឱ្យ អាម្នាក់ ធ្វើជាដេកប្រកាច់មូរនបនៅកណ្តាលផ្លូវ ឃើញដូច្នេះ ខ្ញុំក៏ចុះពីលើឡាន ដើរទៅជិត ... ! "

និយាយដល់ត្រង់កន្លែងនេះ សម្លេងនាងក៏ប្រែទៅជាញ័រ១ ហាក់ដូច ជាខ្ពើមអើមនឹងវត្ថុអ្វីមួយជាទីបំផុត ។

-..."ស្រាប់តែអាប្រកាច់នោះក្រោកឡើង ឯអាម្នាក់ទៀតកញ្ចាស់ ជិតធ្វើស្ទួលដីទៅហើយ ក៏ចាប់ផ្តើមនិយាយផ្តេសផ្តាសពោលតែពាក្យដដែល១ ថា " :

មើល ! បញ្ចេញផ្លែទន្លាប់មើល !

ចំណែកអាក្មេងបន្ថែមថា :

"នែ៎ ! លោកស្រីកុំកាច់រាងពេក ! ... លោកស្រីឯងនេះតាមការពិត សប្បាយចិត្តណាស់ បើសិនជាបាន ... "

ខ្ញុំនិយាយពាក្យនេះ មិនរួចទេលោក ... (នាងយកដៃខ្ទប់មុខ ) ... ខ្ញុំ រៀបតែចូលទៅក្នុងឡានរបស់ខ្ញុំវិញហើយ ស្រាប់តែអាទាំងពីរនាក់នោះ វាលោតមកសង្គ្រប់លើខ្ញុំតែម្តង ។ ... ខ្ញុំខំស្រែកអើយស្រែក ! តែពុំមាននរណាម្នាក់ឮសម្លេងខ្ញុំសោះ ដោយកន្លែងនេះជាស្ថានស្ងាត់ ។ ... ខ្ញុំខំបម្រះពេញទំហឹង តែពុំបានប្រយោជន៏អ្វីសោះ ។ ខ្ញុំត្រូវអាក្មេងចាប់អូសប្រទាញប្រទង់ពីក្រោយ ... ចំណែកអាកញ្ចាស់ ក៏ចាប់ផ្តើមទាញសំពត់ខ្ញុំចេញ ដោយសំពត់ខ្ញុំនោះស្តើងបន្តិចផង វាចាប់ហែកខ្ទេចខ្ទីគ្មានសល់ ។... គ្រាប់ភ្នែកវាលៀនស្ទើរតែជ្រុះនៅពេលដែលវាឃើញខោទ្រនាប់ និងសាច់ភ្លៅរបស់ខ្ញុំ ។ អាដដែលនេះ ក៏ចាប់ផ្តើមប្រឡេះឡេវអាវខ្ញុំ ដៃវាញ័រចំប្រប់ ។ នៅពេលនោះអាក្មេង និយាយចំអកទៅរកគ្នាវាថា :

-"ម៉េច ! លោកពូ អាសត្វហ្នឹងហើយឬ ដែលធ្វើឱ្យលោកពូឯងមិនស្រួលក្នុង ? មើល៍ ! ធ្វើចិត្តឱ្យក្លាហានបន្តិចទៅមើល ! ពូឯងពុំមានពេលណា នឹងបានស្ទាបអង្អែលស្រីរបៀបនេះទៀតទេ ! ... "

វានិយាយពាក្យថោកទាបដូច្នេះជាច្រើនទៀត ... ខ្ញុំខំបម្រះពេញទំហឹង ខ្ញុំប្រឹងទាល់.. ទាល់តែដោះរបស់ខ្ញុំម្ខាងលេចចេញពីអាវទ្រនាប់ ។ គ្រាន់តែឃើញដូច្នោះភ្លាម អានេះចង់សន្លប់តែម្តង ។ ក្នុងឱកាសយ៉ាងខ្លីនោះ វាក៏ស្ទាបអង្អែលច្របាច់ដោះខ្ញុំ ... វាលិទ្ធសព្វកន្លែង ។ ឱ ! ខ្ញុំឈឺ អើយសែនឈឺ !!

"យីផ្លែទន្លាប់នេះល្អណាស់១១១ "វានិយាយពុំចង់ចេញដោយភ្លើងកាមគុណរោលរាលវាខ្លាំងពេក ?

... ឱ ! នេះជាសេចក្តីអាក្រក់ហួសនិស្ស័យ ... ខ្ញុំខ្ពើមរអើមជាទីបំផុត ខ្ញុំរកកល់តែដាច់ដង្ហើមទៅហើយ នៅពេលដែលអាកញ្ចាស់វាទាញហូតខោទ្រនាប់ខ្ញុំទៅលើភ្លៅ ។ ... ចំណែកអាក្មេងវាឱបរឹតខ្ញុំពីក្រោយយ៉ាងណែន ...

និយាយដល់ត្រឹមនេះ នាងទ្រោបខ្លួនទៅលើទ្វាររទ្បាន ។ ខ្ញុំបានស្តាប់ចំហមាត់ ទ្រឹងស្មារតីនឹងរឿងដ៏ចម្លែកអស្ចារ្យ ដែលនាងបានពណ៌នាដោយជាក់លាក់គួរឱ្យព្រឺខ្លួន ។ ខ្ញុំពុំមានចេញស្តីមួយមាត់សោះ ។ ខ្ញុំបើកទ្វាររទ្បានហើយ ធ្វើសញ្ញាឱ្យនាងឡើងមកខាងក្នុងដោយគ្រាន់តែងក់ក្បាលប៉ុណ្ណោះ ។ នាងក៏ញញឹមដោយអាការដឹងគុណ តែនាងពុំបញ្ឈប់ការបរិយាយរបស់នាងឡើយ ។

ដើម្បីបន្ធូបការអៀនខ្មាស ដែលបណ្តាលមកពីរូបកាយអាក្រាតរបស់ នាងខ្ញុំបានហុចភួយពោះគោមួយទៅឱ្យនាង ។ នាងទទួលយកភួយនោះទៅដណ្តប់ខ្លួនប្រាណដោយកក់ក្តៅជាពន្លឹក ។ នាងចាប់បន្លឺសម្លេងនាងតទៀតថា :

-...ពេលនោះអាកញ្ចាស់វាផ្តេកខ្លួនវាជាប់នឹងរាងកាយខ្ញុំ ...វាកកិតស្បែកជ្រីវ ជ្រួញប្រេបនឹងស្បែករបស់ខ្ញុំ ។ ប៉ុន្តែវាចាស់ពេក... វាពុំអាចនឹង...លោកយល់ទេ ? (នាងងើបសម្លឹងភ្លែតមកខ្ញុំរួចដាក់មុខទៅវិញ ...) ចំណែកអាក្មេងវាយក ក្បាលជង្គង់មកទល់ខ្នងខ្ញុំឱ្យអ៊ែនឡើងដើម្បីឱ្យអាកញ្ចាស់ស្រណុកអោបរិតខ្ញុំ ។ ... វាឱប ... វារឹត ... វាច្របាច់ ... វាញីញីខ្ញុំ ... តាមតែអំពើចិត្តរបស់វា ។ ខ្ញុំ ខ្ពើមរអើមរាងកាយគ្មានខ្លឹមសារចង់ក្អួតនឹងក្លិនអសុភរបស់វា ... ខ្ញុំរកកល់តែសន្លប់ទៅហើយ ។

... បន្តិចក្រោយមក អាក្មេងវាទាញអាកញ្ចាស់ឱ្យថយចេញដើម្បីប្តូរវេនឱ្យវា ។ តែអាក្មេងវាត្រូវការច្រើនជាងអាកញ្ចាស់ ។ វាប្រអូសប្រទាញខ្ញុំទៅក្នុងព្រៃគុម្ពោតមួយក្បែរនោះ ... ខ្ញុំបានតស៊ូពេញទំហឹងសូមលោកមើលចុះ ...

នាងបើកបង្ហើបភួយបន្តិចឡើង ដើម្បីបង្ហាញខ្ញុំនូវស្នាមរលាត់ ដែល ជាភស្តុតាងដ៏ជាក់ស្តែង នៃការរំលោភរបស់ទុរជនទាំងពីរនាក់នោះ ។ នាងក៏ទម្រោតខ្លួនបន្តិចទៅលើពូកទ្បានហើយបន្តរឿងទៀតថា :

-... អាក្មេងក៏រុញអាកញ្ចាស់ឱ្យថយទៅឆ្ងាយវាចាប់ផ្តើមឱបក្រសោបខ្លួនខ្ញុំពេញកម្លាំង ។ វាអង្អែល ... ច្របាច់ខ្ញុំសព្វទិសទីដើម្បីទាញអារម្មណ៍ខ្ញុំឱ្យលង់ទៅក្នុងតម្រេក ។ តែអនិច្ចាអើយ នៅពេលនោះខ្ញុំរកកល់តែនឹងក្អួតទៅហើយ ... បន្ទាប់មកខ្ញុំក៏សន្លប់បាត់ស្មារតី ... អាក្មេងប្រហែលបានសម្រេចទៅហើយ !!! ។

នាងនិយាយទៅទៀតពុំរួច ដោយអួលដើមកជាខ្លាំង ។

-... ៉លុះខ្ញុំដឹងខ្លួនឡើងវិញ ពួកវាបានរត់ទៅបាត់អស់ដោយប្រមូល យកទៅជាមួយនូវរបស់របរ ដែលខ្ញុំមានទាំងប៉ុន្មាន ...

ស្ងៀមមួយស្របក់ ... នាងងាកមករកខ្ញុំ ហើយដាក់ដៃនាងមកលើ ដៃខ្ញុំ ដោយញញឹមយ៉ាងស្រស់ ។

-ខ្ញុំសូមអរគុណលោកជាទីបំផុត ! ...

កាលដែលនាងបានពាល់ដៃខ្ញុំនោះ បេះដូងខ្ញុំកញ្ជ្រោលយ៉ាងខ្លាំង ហាក់បីដូចជាមានដែកឆក់អ្វីមួយមកបញ្ឆោ ។ ខ្ញុំមានសេចក្តីលំបាកជាទីបំផុត ដើម្បីទប់វិញ្ញាណខ្ញុំកុំឱ្យលង់ទ្រនេសនៅពេលដែលខ្ញុំក្រឡេកឃើញគល់ដោះដ៏ក្បូររបស់នាង ។ រឿងហេតុដែលនាងបានរៀបរាប់អម្បាញ់មិញ បានធ្វើឱ្យខ្ញុំរសាប់រសល់ជាទីបំផុត ។ ខ្ញុំពុំហ៊ានស្តីពោលអ្វីមួយម៉ាត់សោះ ព្រោះខ្លាចក្រែងនាងសំគាល់ដល់សម្លេងស្រៀវស្រាញរបស់ខ្ញុំ ។ គឺជាគ្រោះល្អពេលនោះ, ភ្លើងដ៏ស្រទន់នៅក្នុងរថយន្តពុំអាចឱ្យនាងសំគាល់ដល់ការប្រែប្រួលរបស់ខ្ញុំបានឡើយ ។ ខ្ញុំកញ្ឆោះរថយន្តហើយបើកទៅមុខទៀត ។ ខ្ញុំលួចមើលស្រីនោះម្តងៗ, ឱ ! នារីនោះល្អមែនទែន ធ្វើឱ្យខ្ញុំមានចេតនាលេបទឹកមាត់ ។ ភ្នែកនាងខ្មៅយង់, ច្រមុះនាងត្រង់ស្រួច, ត្រួវនឹងបបូរមាត់ស្តើងបន្តិចសមឥតខ្ចោះ... នាងប្រហែលជាអ្នកមានឋានៈខ្ពង់ខ្ពង់គួរសមដែរ ។ នាងពុំគួរមកប្រទះនូវការដ៏ម៉ាស់មុខយ៉ាងដូច្នេះសោះ ។ ឱ ! បើសិននាងស្លៀកពាក់ត្រឹមត្រូវប្រហែលជាខ្ញុំលួង ប្រលោមនាងភ្លាម ។ តែរូបកាយអាក្រាតរបស់នាង ដែលគ្រាន់តែមានភួយគ្របពីលើបន្តិចប៉ុណ្ណោះ ធ្វើឱ្យខ្ញុំរួញរាជាទីបំផុត ។

យើងទាំងពីរនាក់ ពុំមានឆ្លើយឆ្លងរកគ្នាបន្តិចសោះអស់រយៈពេលដ៏យូរ ។

យូរៗកន្សែងពោះគោរបើកឡើងម្ដងៗ ធ្វើឱ្យលេចសាច់ភ្លៅសស្គុស ។ វេលាដែលនាងទាញតម្រឹមមកវិញ គឺដល់វេនសុដន់មួយមូលក្បុំផុសធ្លោឡើងម្ដង ។

វាយោរាត្រីត្រជាក់បក់ផាត់ មកគ្របដណ្ដប់ពាសពេញផ្លូវថ្នល់ ។ សន្សើមបក់ភាយៗមកលើផ្ទៃរថយន្តខ្ញុំ ធ្វើឱ្យនាងរងារណ្ដុំថ្កាមក្រឹតៗ ។ លុះឃើញដូច្នោះ ខ្ញុំក៏សម្រេចចិត្តនិយាយទៅរកនាងខ្លះ ដើម្បីញ៉ាំងបរិយាកាសកុំ ឱ្យតឹងតែង ។

-ឱ ! នាងមុខជារងាស្លាប់ហើយ ... តែបន្តិចទៀតយើងនឹងទៅដល់កែបនោះ នឹងមានផ្ទះសំណាក់ស្រួលបួលហើយ ។ ... នាងចូលទៅសម្រាកក្នុង ផ្ទះសំណាក់នោះទៅទុកភារៈឱ្យខ្ញុំនិយាយទូរស័ព្ទទៅកាន់ភ្នាក់ងារប៉ូលិស ដើម្បីប្ដឹងរាយការណ៍អំពីគ្រោះថ្នាក់របស់នាង ។

ឮដូច្នោះ នាងឈ្ងោកក្បាលទៅមុខបន្តិច ហាក់ដូចជាជញ្ជឹងគិតរឿងអ្វីមួយសម្ងើមណាស់ ។ រួចនាងងើបក្បាលឡើងនិយាយថាៈ

-... "លោកគិតយ៉ាងហ្នឹងត្រូវហើយ ! ..."

នាងក៏ផ្អែកខ្លួនទៅលើពូកឡាន ដោយបិទភ្នែកកព្រឹមៗ រំពេចនោះ នាងភ្ញាក់ព្រើត ហាក់ដូចជានឹកឃើញរឿងសំខាន់អ្វីមួយ ។ នាងច្របច់ដៃមកលើ ភ្លៅខ្ញុំ ហើយបន្លឺវាចាថា :

-... សូមលោកស្ដាប់ខ្ញុំ សូមកុំយល់ច្រឡំលើរូបខ្ញុំឱ្យសោះ (នាងបើកភ្នែកធំៗ ដើម្បីបញ្ជាក់ឱ្យខ្ញុំជឿ ) ខ្ញុំដឹងថាលោកជាមនុស្សមានកិត្តិយស លោកពុំរំលោភលើភេទទន់ខ្សោយរបស់ស្ត្រីទេ ... សូមលោកកុំចោលខ្ញុំឱ្យសោះយប់នេះ ខ្ញុំខ្លាចណាស់ ... ខ្ញុំនៅតែស្រមៃឃើញអាយូកូងពីរនាក់នោះជាដរាប ។ លោក... ខ្ញុំសូមអង្វរ ... ខ្ញុំពុំហ៊ាននៅម្នាក់ឯងទេ ... សូមលោកប្រាប់ខ្ញុំបន្តិចមើល តើលោកយល់ចិត្តខ្ញុំទេ ?

-ខ្ញុំយល់ហើយនាង ! ខ្ញុំនិយាយដោយទន់សម្លេងកុំឱ្យញ័រ ... ខ្ញុំ អរគុណនាងណាស់ ដែលនាងមានសេចក្ដីទុកចិត្តលើរូបខ្ញុំដូច្នេះ ។ នេះជាភារៈ ខ្ញុំហើយ ដែលត្រូវការពារនាង ... តែចូលនាងគិតមើល ... តើធ្វើមេច្ចនឹងគេ ព្រមឱ្យយើងចូលទៅក្នុងបន្ទប់ទាំងពីរនាក់បាន ? ... យើងពុំមែនជាប្ដីប្រពន្ធ នឹងគ្នាផង !!! នាងដឹងទេ ? ... ពួកម្ចាស់ផ្ទះសំណាក់គោរពច្បាប់ណាស់នៅស្រុកនេះទុកជានាងខំពន្យល់គេយ៉ាងណាក៏ដោយ ហើយម្យ៉ាងវិញទៀតដូចជា ជ្រាបស្រាប់ហើយ គេពុំសូវជឿទេរឿងចោរលួច ប្លន់ ។

ឮដូច្នោះនាងក៏ខំប្រកែកយ៉ាងខ្លាំង ។

-រួចចុះបើរឿងនេះជារឿងពិត ម្ដេចក៏បានជាគេមិនជឿ ? ខ្ញុំមានយល់សប្ដិឯណា ? ... សូមលោកមើលចុះ !

នាងក៏បង្ហើបកន្សែងពោះគោឡើង បង្ហាញសំណាមជាំៗដែលជាភស្តុតាងនៃការប្រវាយប្រតប់គ្នា, ខ្ញុំតបវិញថា :

-ចំណែកខ្ញុំៗជឿនាងដោយឥតរង្កៀសសង្ស័យបន្តិចទេ, ប៉ុន្តែ ពួក អស់នោះវិញពិបាកបន្តិច ។

ស្ដាប់សម្ដីខ្ញុំដូច្នោះ នាងក៏មានអាការស្រងូតស្រងាត់ជាខ្លាំងធ្វើឱ្យខ្ញុំ អាណិតក្រៃពេក ។

-ឱ ! នាង ខ្ញុំនឹកឃើញហើយ (ខ្ញុំនិយាយឡើង ដោយគិតមួយស្របក់ )... ខ្ញុំឃើញរបៀបមួយស្រួលណាស់ ។ ... នៅជាប់នឹងផ្ទះសំណាក់នីមួយៗ មានកន្លែងទុកឡានស្រួលបួល ខ្ញុំយកនាងបញ្ចូលក្នុងបាំងខាងក្រោយ ពួកអ្នកយាមប្រាកដជាពុំមកឆែកឆេរឡាននេះឡើយ ។ លុះទៅដល់ក្នុងរោងឡាន ខ្ញុំនឹងអាចបណ្ដោះនាងឱ្យចូលទៅក្នុងបន្ទប់ខ្ញុំបានយ៉ាងស្រួល ... ចាំស្អែក ខ្ញុំទៅទិញសំពត់អាវសម្រាប់នាង ហើយនាង នឹងអាចទៅប្រាប់ហេតុការណ៍ដល់ភ្នាក់ងារប៉ូលិស ដោយគ្មានការអៀនខ្មាស !

នាងញញឹមយ៉ាងស្រស់មករកខ្ញុំ ដោយការដឹងគុណ ខ្ញុំសប្បាយស្ទើរអណ្ដែតខ្លួន ។

-ចាំ ! ... លោកមានយោបល់ល្អណាស់ !

នេះជាសម្ដីដ៏ទន់សមតាមកាយវិការរបស់នាង ។ គឺជាលើកដំបូង ដែលខ្ញុំឃើញនាងសប្បាយចិត្ត ។ អារម្មណ៍រីករាយនេះ ហើយធ្វើឱ្យនាងរឹតតែល្អឡើងៗ ។ លុះនៅសល់តែមួយគីឡូម៉ែត្រទៀតនឹងទៅដល់កែប ខ្ញុំក៏បញ្ឈប់រថយន្តភ្លាម ។ ខ្ញុំចុះទៅបើកគម្របខាង

ក្រោយឡាន ។ ដកយកហិបស្បែកមួយយ៉ាងធំចេញមក ... ។ បន្តិចក្រោយមក នាងដើរឆ្ពោះមក ដោយខំចំអើត ជើងទម្លាក់ដូចជាស្រីដែលធ្លាប់តែពាក់ស្បែកជើងកែងចោតអញ្ចឹង ។ កន្សែងដែលនាងដណ្តប់នោះ ពុំអាចបិទបាំងរាងកាយឱ្យបានជិតជាល្អទេ ម្តងលេចមុខម្តងលៀនក្រោយប្រផុតប្រផើយ ធ្វើឱ្យខ្ញុំចង់ភ្លាត់ស្មារតីម្តងៗ។

-យ៉ាងម៉េចទៅលោក ? នាងនិយាយដោយជ្រងសក់ដែលមានពណ៌ ខ្មៅស្រិលដូចស្លាបសារិកា ។ ខ្ញុំភ្ញាក់ពីការភ្លឹងភ្លាំងហើយជួយរុញបញ្ចូលនាង ទៅក្នុងគូថឡាន ។ នាងឈ្ងោលខ្លួនចូលទៅក្នុងយ៉ាងពិបាក ដោយទាញក្បាល ជង្គង់បត់ទល់នឹងចង្កា ។

-ខ្ញុំនឹងអង្គុយក្នុងនេះស្រួលទៅបាន ទាល់តែខំឱបក្បាលជង្គង់ ... ក៏ប៉ុន្តែភួយនេះទើសទែងរំខានខ្លាំងណាស់ ។

ខ្ញុំនៅស្ងៀមពុំអាចឆ្លើយអ្វីបានមួយម៉ាត់សោះ ។

-សូមលោកស្តាប់ខ្ញុំ ... ខ្ញុំមានសេចក្តីអៀនខ្មាសស្ទើរស្លាប់ទៅហើយតែធ្វើម្តេច ? ... យើងត្រូវតែទៅឱ្យដល់កន្លែងនោះជាដាច់ខាត ។ ... បើដូច្នោះ សូមលោកទាញភួយចេញពីខ្ញុំផងហើយសូមឧបមាថាទុកខ្លួនខ្ញុំដូចជាហិបមួយ ទៅចុះ ! ...

ខ្ញុំនឹកថា : "ស្រីនេះមានចរិយាតស៊ូណាស់ ចេះសម្រេចចិត្តក្នុងការវេលាដ៏សែនពិបាក " ។ ខ្ញុំធ្វើតាមបង្គាប់នាងដោយសប្បាយចិត្តទៀតផង ។ រំពេចនោះ ខ្ញុំឈ្ងោលក្បាលចូលទៅក្នុងដៃម្ខាងលើកនាងបង្ហើបបន្តិចឡើង រីឯដៃម្ខាងទៀត ទាញអូសយកភួយសន្សឹមៗចេញមក ។ នាង ងាកក្បាលចេញបន្តិច ដើម្បីបន្ធូរការអៀនខ្មាស ។ ខ្ញុំស្រៀវរបះសក់ ដោយឃើញរូបកាយនាងអាក្រាតទាំងអស់ដៃខ្ញុំបានប៉ះពាល់លើចង្កេះដែលមានរាងសែនក្លំ, ភ្នែកខ្ញុំក្រឡេក ឃើញរន្ធផ្ចិត ឃើញភ្លៅទាំងគូរវែងស្រលូតអួត នឹងសម្រស់ធ្វើឱ្យខ្ញុំពិបាកអត់ទ្រាំយ៉ាងក្រៃលែង ។ ពេលដែលខ្ញុំលូកដៃក្រសោបអង្គប្រាណ ប្រុងនឹងជម្រុញខ្លួននាងឱ្យចូលស៊ប់ទៅក្នុងខ្ញុំសម្ងំចីនអស់មួយស្របក់ដោយដឹងថាសុដន់មួយ បាននៅផ្ទោបជាប់នឹងដើមទ្រូងខ្ញុំយ៉ាងសែនកក់ក្តៅ ។ ឯដៃខ្ញុំ ដែលរុំចង្កេះនាងមានភាពញ័រទទ្រើក ! ខ្ញុំក៏បិទគម្របឡានយ៉ាងស្រួល ប៉ុន្តែមិនឱ្យជិតសោះនោះទេ ។ លុះខ្ញុំត្រឡប់ចូលក្នុងឡានស្រេចបាច់ហើយ ខ្ញុំទាញទ្វារបិទយ៉ាងខ្លាំង ដើម្បីដាស់សតិខ្ញុំឱ្យចេញផុតពីការភ័ន្តភាំង ។ រួចខ្ញុំបញ្ជោរថយន្តចេញទៅមុខភ្លាម ។

ដប់ប្រាំនាទីក្រោយមក... ខ្ញុំមានសេចក្តីរីករាយជាអនេកដោយឃើញថា គ្រោងការដែលខ្ញុំគិតមកនោះ បានសម្រេចដូចបំណង ។ ឯអ្នកយាមផ្ទះ សំណាក់ ដែលមានលំនៅផ្ទាល់ខ្លួនជាប់នឹងទ្វាររបងពុំមានការសង្ស័យអ្វីសោះឡើយ ។ គេគ្រាន់តែយកបញ្ជីមកឱ្យខ្ញុំចុះឈ្មោះតាមកាត ហើយហុចសោទ្វារបន្ទប់ឱ្យខ្ញុំ ដោយចង្អុលប្រាប់ទិសដែលត្រូវទៅប៉ុណ្ណោះ ។ ខ្ញុំសង្កេតឃើញដោយសោមនស្សជាខ្លាំងថាកន្លែងទាំងឡាយដែលសម្រាប់ជួលសំណាក់ស្ថិតនៅឆ្ងាយពីគ្នា ។

លុះយើងទាំងពីរនាក់ បានចូលដល់ក្នុងផ្ទះសំណាក់ហើយ ខ្ញុំក៏ប្រញាប់ ប្រញាប់បើកភ្លើងឡើង ដើម្បីឱ្យភ្លឺដល់ក្នុងបន្ទប់ ។ រំពេចនោះ អំពូលជាច្រើនបានចោលរស្មីក្រអៅ បង្ហាញដល់ចក្ខុយើងនូវប្រដាប់ប្រដាទាំងឡាយ ដូចជា តុ តូចៗពីរ គ្រែមួយធំល្មមតែទាបបន្តិចកៅអីសម្រាប់ទម្រេត ។ ល។ នៅលើ តុមានថូមួយប្រកបដោយបុប្ផាចម្រុះពណ៌ បញ្ចេញនូវគន្ធពិដោរឈ្ងុយឈ្ងប់ពេញទាំងផ្ទៃបន្ទប់ ។ ខ្ញុំក៏ប្រញាប់ប្រញាល់ទៅបិទវនាំងបង្អួច ដើម្បីកុំឱ្យគេ មើលពីក្រៅឃើញស្រមោលស្រី ដែលខ្ញុំនាំមកជាមួយ ។

-កន្លែងនេះសប្បាយណាស់ , កំពុងតែស្រាយនំខ្ញុំងាករកមើលនារីនេះ មិនឃើញសោះ តែខ្ញុំឃើញក្បាលនាងអើតចេញ ពីបន្ទប់ទឹកមកនិយាយថា :

ខ្ញុំងូតទឹកហើយ ដើម្បីឱ្យជ្រះចង្រៃ សូមលោកពិសានំនោះចុះ កុំចាំខ្ញុំ អី ខ្ញុំទុកទ្វារចំហ ដើម្បីស្រួលនិយាយគ្នា ! ...

-មិនអីទេនាង ! ងូតទឹកចុះ ... ខ្ញុំក៏ពុំសូវឃ្លានប៉ុន្មានដែរ !

និយាយហើយ ខ្ញុំក៏ទុកប្រអប់នំនៅលើតុ រួចខ្ញុំរើហិបយកអាវបំពង់ពីរចេញមក ។ អាវនោះវែងសម្រាប់ពាក់ដេក, ខ្ញុំយកអាវមួយហុចទៅឱ្យនាង ដោយគ្រាន់តែលូកដៃចូលក្នុងបន្ទប់ទឹកប៉ុណ្ណោះ ។ សម្លេងទឹកផ្កាឈូកធ្លាក់ចុះ ឈូឆរ តែនាងឆ្លៀតឱកាសនិយាយពីក្នុងបន្ទប់មកថា :

-... អូ ! ខ្ញុំភ្លេចជំរាបលោកឈឹង ថាខ្ញុំឈ្មោះរថា ! ....

-ឱ ! ឈ្មោះនាងល្អណាស់, ចំណែកខ្ញុំវិញកុយពីជិត ឈ្មោះរថា ហើយ មានស្អីទៀតដែរ ?

-... ឈ្មោះខ្ញុំមានតែរថាប៉ុណ្ណោះទេ ពុំមានស្អីទៀតទេ ។ សូម លោក កុំចង់ដឹងឈ្មោះមួយទៀត ពីព្រោះឈ្មោះមួយទៀតនោះ នរណាក៏គេស្គាល់ដែរ ហើយខ្ញុំពុំចង់រឿងនេះជ្រាបដល់ឪពុកខ្ញុំសោះ ។ គ្រាន់តែបាត់ឡានប៉ុណ្ណឹងមិនអីទេ ប៉ុន្តែប្រយ័ត្នតែគាត់ដឹងរឿងថាមានប្រុសមករំលោភលើខ្ញុំនោះ គាត់នឹង ខឹងសម្បារស្លាប់ហើយ ! ...

ខ្ញុំដូចពុំសូវជឿប៉ុន្មាន ពាក្យដែលនាងបានថ្លែងមកនេះ នាងខ្លាច ឪពុកនាងដឹង ប៉ុន្តែតាមមតិខ្ញុំ ខ្ញុំយល់ថាប្រហែលជា នាងខ្លាមប្រុសនាងទេមើល ទៅ !

-លោកមិនសង្ស័យខ្ញុំទេឬ ? ខ្ញុំសូមជំរាបលោកឈ្មោះខ្ញុំប្រហែលជា ពុំមែនថាផងមើលទៅ !

-សូមនាងកុំព្រួយ ខ្ញុំពុំរំខានកិច្ចការនាងទេ !

-ចាំះ ! ខ្ញុំអរគុណលោកជាទីបំផុត, លោកជាបុរសមានចរិយាស្លូត បូតត្រឹមត្រូវណាស់ ។ លោកដឹងទេ ? ខ្ញុំមានអាយុ ២២ ឆ្នាំទៅហើយ ប៉ុន្តែ ឪពុកខ្ញុំនៅថ្នាក់ថ្នមហាក់ដូចកូនខ្ចីនៅឡើយ !!

ឈប់មួយស្របក់នាងបន្ថែមថា :

-ខ្ញុំចូលចិត្តវាំណាស់លោក ចុះចំនែកលោកវិញ តើចូលចិត្តដែលឬ ?

-ខ្ញុំក៏ចូលចិត្តដូចនាងអញ្ចឹងដែរ ! ... ថ្ងៃណាមួយយើងមុខជាបានជួបគ្នានៅរង្គសាលម្តង, នោះយើងនឹងអាចរាំទាំងពីរនាក់យ៉ាងសប្បាយ !

-មែនឬលោក ? ឱ ! បើដូច្នោះខ្ញុំសប្បាយចិត្តណាស់ !

វេលានោះ ខ្ញុំនឹកព្រួចដល់ការរៀបចំកន្លែដេក, ខ្ញុំយកភួយមួយមកក្រាលជិតគ្រែ ហើយទាញយកខ្នើយមួយមកដាក់លើកំរាលនោះផង ។ នាងរថាក៏ចេញពីបន្ទប់ទឹកល្មម, ខ្ញុំងើបមើលនាងធ្វើភ្នែកស្លឹង ។

-លោកកំពុងធ្វើអ្វីហ្នឹង ? (នាងនិយាយដោយញញឹម)

លុះឃើញខ្ញុំកាន់ខ្នើយនៅដៃ នាងបន្ថែមថា :

-យី ! លោកទុករបស់របរអស់ទាំងនេះទៅ, ចាំខ្ញុំរៀបចំជូន ! ...

នាងឆក់ខ្នើយពីដៃខ្ញុំ ដែលកំពុងតែឈរភាំង..លុះដល់នាងលុតជង្គង់ ហើយឱនរៀបចំកន្លែង ឱ្យមានសណ្តាប់ធ្នាប់ល្អនោះ ខ្ញុំមើលពីក្រោយទៅឃើញប្រឡោះគល់ភ្លៅនាងលេចជ្រងោ ។ ... ខ្ញុំព្រឺព្រួចគ្រប់រោមខ្ញុំស្ទុះគេចរហ័ស ទៅក្នុងបន្ទប់ទឹកដោយខ្លាចក្រែង ខ្ញុំភ័ន្តសតិបណ្តាលឱ្យប្រព្រឹត្តខុសតម្រាទៅលើរូបនាង ។ តម្រេកទាំងប៉ុន្មាន ត្រូវនឹងទឹកត្រជាក់បានបន្ថយសកម្មភាពរបស់វាអស់ជាច្រើន ។ បន្តិចក្រោយម ខ្ញុំក៏ចេញពីបន្ទប់ទឹកមកវិញ ខ្ញុំឃើញ រថាកំពុងទ្រោបលើពូក គោះជើងបណ្តើរច្រៀងបណ្តើរ ... ឱ ! ប្រហែលនាងភ្លេចគ្រោះកាចអពមង្គលនោះហើយមើលទៅ ។ ខ្ញុំដៀងភ្នែកទៅលើតុ ឃើញនំអស់កន្លះប្រអប់ នាងឃ្លានខ្លាំងណាស់បានជាបរិភោគច្រើនម្លឹង១ ប្រហែលជានាងអស់កម្លាំងណាស់ហើយមើលទៅ ។ រាងកាយចង្រៃរបស់ខ្ញុំចាប់ផ្តើមកំរើកញាប់ញ័រទៀតហើយ ដោយខ្ញុំឃើញខ្លួននាងរថា ។ ខ្ញុំក៏ប្រញិបប្រញាប់អង្គុយចុះ លើក្រមាលដំណេកខ្ញុំភ្លាម ។ ខ្ញុំឈោងយកនំពីរបីមកទំពា ហើយនិយាយអរគុណនាងដែលបានរៀបចំដំណេកខ្ញុំឱ្យបានស្រួលបួល ។

-សូមលោកកុំអរគុណខ្ញុំអី នេះជាការបន្តិចបន្តួចទេ !

-នាងម៉េចក៏មិនញ៉ាំនំទៀតទៅ ?

-មិនអីទេលោក ! ខ្ញុំឆ្អែតស្រេចហើយ ... ។

ពេលនោះខ្ញុំមើលទៅមុខនាង រាងដូចជាងុយងោកសម្បើមណាស់ ខ្ញុំ របូតមាត់សួរថា :

-នាងឱ្យខ្ញុំពន្លត់ភ្លើងគេងឬ ?

-ចាំះ ! អញ្ចឹងក៏បាន ព្រោះទម្លាប់ខ្ញុំមិនដែលគេងមានទុកភ្លើងទេ !

រំពេចក្រោយមក បន្ទប់យើងមានភាពងងឹតឈឹង , យើងទាំងពីរនាក់សណ្ដូកខ្លួនក្បែរគ្នា គ្រាន់តែនាងនៅលើគ្រែខ្ពស់ជាងខ្ញុំប្រហែលជាបីតឹកប៉ុណ្ណោះ ចំណែកខ្ញុំៗគេងផ្ទាល់នឹងកម្រាលឥដ្ឋ ។

-...ខ្ញុំអរគុណលោកមិនភ្លេចទេ ! (នេះជាសម្លេងដែលនាងនិយាយ ខ្សាវ ៗ) ។

រស្មីព្រះចន្ទភ្លឺថ្លា ហើយស្រទន់ ជ្រែងតាមស្លាបព្រិល និងប្រហោងជញ្ជាំងចូលមកក្នុងបន្ទប់ ។ នៅពេលជាមួយគ្នានោះខ្ញុំឃើញនាងទម្លាក់ដៃចុះ ពីលើគ្រែរួចចាប់អង្អែលដៃខ្ញុំថ្នមៗ ។

-...ខ្ញុំអរគុណលោកជាទីបំផុត ,

ខ្ញុំទ្រាំពុំបានក៏ដាច់ចិត្តអង្អែលដៃនាងវិញដែរ, ខ្ញុំជម្រុលដៃខ្ញុំឱ្យឡើងតាមប្រឡោះដៃអាវបំពង់របស់នាង ។ នៅទីបំផុតចុងដៃរបស់ខ្ញុំ ក៏ពើបប្រទះ នឹងសុដន់ដ៏ក្បូរបស់នាង ... ខ្ញុំព្រឺខ្លួនបះរោមច្រាង ... ។ ក៏ប៉ុន្តែនាងពុំប្រកែក ឬរុញដៃខ្ញុំចេញសោះឡើយបន្តិចម្ដងៗដៃខ្ញុំក៏អង្អែលទ្រូងនាងទាល់តែគ្រប់សព្វទាំងអស់ ។ រួចខ្ញុំលើកដៃគ្របសង្កត់លើដោះព្រីប ហើយច្របាច់ថ្នមៗ ។ ខ្លួននាងចាប់ផ្ដើមរមួលហើយមានសភាពញ័រៗ ។ នៅចន្លោះមេដៃ និងចង្អុលដៃខ្ញុំ កៀបក្បាលដោះមូរចុះឡើងបន្តើរៗ បណ្ដាលឱ្យដងខ្លួនល្វតល្វៃរេចុះរេឡើងដូចអន្ទង់ ។ ខ្ញុំងើបឡើងបន្តិច ហើយគ្រវាត់ខ្មើយឱ្យទៅឆ្ងាយ ។ ខ្ញុំបានចិត្តណាស់ ... ខ្ញុំនឹកស្មានថាមិនអីទេ ព្រោះក្នុងការចាប់អង្អែលសុដន់បានយ៉ាងស្រួល ហើយនារីតែងតែស្លូតនៅពេលជាបន្ទាប់ ។ ដៃខ្ញុំម្ខាងទៀតរាវរកភ្លៅ នាងនៅក្រោមភួយ រួចរំអិលចុះឡើងតាំងពីក្បាលជង្គង់ទល់នឹងគល់ភ្លៅ ។ ខ្លួននាងមានការប្រែប្រួលក្ដៅភាយៗញ័រៗខ្លាំងឡើងៗជាលំដាប់ ។ ដៃខ្ញុំធ្វើដំណើរទៅមុខជានិច្ច ...

លុះដល់ប្រឡោះភ្លៅ ដូចជាមានរបស់អ្វីមួយមកបញ្ឈប់ ឬដូនជាគយឆែកឆេរនៅទីនោះយ៉ាងយូរ ... ។ រថានាងដកដង្ហើមស្ទើរមិនចង់ដល់គ្នា ។ នាងទាញភួយបោះចោលទៅឆ្ងាយពីខ្លួន ។ ដងខ្លួននាងរមួលរំពើត ។

-អូយ ! បងពីជិតអើយ ! សូមមកឱ្យឆាប់ៗអូនទ្រាំទៅទៀតពុំបាន ទេ ...

ឮដូច្នោះខ្ញុំក៏ស្ទុះងើបឡើងជាបន្ទាន់ ហើយឈ្មុលក្បាលចើបគត់ភ្លៅ នាងដោយអាការស្រេកឃ្លានពន់ប្រមាណ ។ នាងបោចសក់ខ្ញុំ ហើយទាញក្បាលខ្ញុំទៅទំលាក់លើដោះនាងហាក់បីដូចមាតាទាញទារកឱ្យបៅ ។ ខ្ញុំស្រូបជញ្ជក់ញេចញេញសង្កៀតគ្មានត្រាប្រណី ។

-ឱ ! ឆ្ងាយអ្វីឆ្ងាញ់ម្ល៉េះហ្ន៎ ... ឆ្ងាញ់រកពាក្យប្រដូចគ្មាន ។

ខ្លួននាងញ័រទទ្រើត ដូចជាកូនសត្វបក្សី ទើបតែនឹងញាស់ ឬដូចជាស្លឹករុក្ខជាតិ ត្រូវកម្លាំងវាយោបក់បោកអញ្ចឹង ។ ក្រចកនាងដែលខ្វាំសក់ខ្ញុំ បានធ្វើ ឱ្យមុតលលាដ៏ក្បាល ហើយបានធ្វើឱ្យខ្ញុំរឹតតែសាហាវឡើងទៀតក្នុងការបំរើតម្រេត ។

លុះឃើញនាងផុងខ្លួនស្ទុង ទៅក្នុងអន្លង់នៃកាមគុណហើយ ខ្ញុំក៏ងើបឈរឡើងកន្ត្រាក់អាវបំពង់ចេញយ៉ាងខ្លាំងរួចគ្រវាត់ត្រឡប់ត្រឡិល ... ក្នុងកាយវិការដូចយល់សប្តិនេះ ខ្ញុំបានទាត់កែវមួយរមៀលតួងតាង .. តែប៉ុណ្ណោះ ខ្ញុំលែងទាញចក្ខុឱ្យចេញផុតពីខ្លួនរបស់នាងរថាហើយ ។

ក្បាលនាងពេនពន់ចុះឡើង ដូចប្រមោយដំរី, ខ្ញុំទ្រាំទៅទៀតពុំបានទេ ឯចំនែកនាងវិញក៏ដូច្នោះដែរ ... ។ ខ្ញុំក៏លោតទៅសង្គ្រប់លើនាងតែម្ដង ។ ភ្លៅនាងក៏កន្ត្រែកឡើងសន្សឹមៗ ដើម្បីទទួលខ្ញុំឱ្យចូលឈ្មុលចូលទៅនៅប្រឡោះកណ្ដាល ។

ទីបំផុតខ្លួនខ្ញុំក៏ទ្រោបលើខ្លួននាងយ៉ាងពេញទំហឹង ! ...

យើងទាំងពីរនាក់ក៏ឱបក្រសោបគ្នា គ្មានសំចៃកម្លាំងក្នុងចង្វាក់ដ៏សែនញាប់ញ័រ ។ មាត់យើងទាំងពីរជញ្ជាក់គ្នាពុំមានឈប់ឈរ ។ យើងភ្លេចអស់នូវ ទុក្ខព្រួយទាំងប៉ុន្មាន ។ ភ្លេចអស់នូវបញ្ហាអ្វីៗទៀតក្នុងពិភពលោក ។ ដៃរថា ទាំងពីរឱបកខ្ញុំយ៉ាងស្វិតស្វាញ ហើយទាញខ្ញុំឱ្យទៅជ្រមុជជ្រមុលនាងដោយសេចក្តីសុខស្រួលរកអ្វីប្រៀបគ្មាន ។

លុះក្រោយបន្តិចមក ខ្ញុំឃ្លាតចេញពីខ្លួនរថា ។ ខ្ញុំនឹកថាខ្ញុំពុំដែលស្គាល់រសជាតិស្នេហា ឯណាដែលមានអានុភាពយ៉ាងដូច្នេះសោះ ។ ខ្ញុំក្រឡេកមើល ទៅនាងឃើញដេកស្ងួកស្ងឹងដូចជាមនុស្សឥតវិញ្ញាណនាងងាកមុនមករកខ្ញុំ ដោយរីករាយ. នាងបង្អិតខ្លួនមកជិតខ្ញុំទាល់តែត្រគាកទង្គិចនឹងត្រគាក ។ ខ្ញុំក៏ងាកទៅរកនាងយកដៃមួយក្រសោបនាង ហើយយើងទាំងពីរនាក់ក៏បណ្តែតអារម្មណ៍ទៅទៀត ដោយដេកខ្លួនទល់នឹងខ្លួន ដង្ហើមឥតដល់គ្នា ។

-... បង ( សម្លេងនាង ) ... អូនប្រាប់បងឱ្យត្រង់ទៅចុះតាំងពីដើមមកអូនពុំដែងស្គាល់ស្រណុកអីស្រណុកអញ្ចឹងទេ ...

ខ្ញុំក៏និយាយប្រាប់នាងវិញថា ខ្ញុំក៏ដូច្នេះដែរ ។

ពេលនោះ រថានាងក្រោកឡើងទាញយកអាវបំពង់មកពាក់ ហើយ ដើរតម្រង់ទៅបន្ទប់ទឹក ។

បន្តិចក្រោយមក ខ្ញុំងើបទៅបើកភ្លើង ដើម្បីរៀបចំដំណេកឱ្យបានស្រួលបួលឡើងវិញ ។ ម្តងណេះខ្ញុំមិនចាំបាច់គេងខាងក្រោមដូចមុនទៀតទេ ។

លុះរថាចេញពីបន្ទប់មកវិញ ទឹកមុខនាងស្រស់បំព្រង់ដូចដើម ។

-ខ្ញុំឃ្លានណាស់បង !

-អូនឯងមិនញ៉ាំនំទៅ ... នៅសល់សន្ធឹក !

នាងក៏ទៅយកនំពីលើតុមកដាក់លើពូក ហើយអង្គុយទំពាក្រូបៗ ។

-អូនញ៉ាំច្រើនណាស់បង ! ... បងប្រាប់អូនមើល បងស្អប់ទេស្រីដែល ញ៉ាំច្រើន ... អូនញ៉ាំពុំដែលមានរបៀបរបបទេ ញ៉ាំទាល់តែហល់បានសម្រាក ។ ... ប៉ុន្តែអូនឆ្ងល់ណាស់ អូនពុំដែលធាត់ ឬឡើងទម្ងន់បន្តិចសោះ !

-ចំណែកបងគ្មានឆ្ងល់បន្តិចទេ ! តែញ៉ាំច្រើនវា Surmenage រួចមក ពីអូនឯងចំណាយច្រើនពេកបានជាដូច្នេះ !

ខ្ញុំនិយាយដោយបញ្ចេញសំណើចបន្តិចផង ។

-បងស្មានថា អូនគិតខុសឬ ? ដែលអូនចំណាយច្រើន ... ?

-ហាស ! ហាស! ( ខ្ញុំសើចតិច ៗ ) បងមិនរមិលគុន

ថាហើយ ខ្ញុំឱបក្រសោបនាង ហើយជញ្ជាក់មាត់នាងយ៉ាងយូរ ។ ខ្ញុំ មើលប្រអប់នំឃើញអស់រលីង ។

-អូនឯងនៅឃ្លានទៀតឬ ?

-ចាស ...

ខ្ញុំងើបឡើងដើរតម្រង់ទៅហិបស្បែក ហើយរាវយកស៊ូកូឡា (chocolat) ពីរដុមហុចឱ្យនាង ។ ពេលដែលនាងខាំទំពាស៊ូកូឡាខ្ញុំឡើងទៅ ទម្រេតខ្លួនស្ងួកនៅលើគ្រែ ។

អាវនាងចំហឡើង ធ្វើឱ្យខ្សែចក្ខុខ្ញុំបាញ់តម្រង់ទៅម្តុំត្រីកោណទិព្វ ។ នាងឃើញភ្នែកខ្ញុំដូច្នោះ ក៏ចូលមកអង្អែលខ្ញុំរួចថើបខ្ញុំ ។ មិនយូរប៉ុន្មានទុព្វល ភាព បណ្តាលពីការងោកងុយបានទាញព្រលឹងយើងឱ្យលក់ស្កប់ស្កល់ស្ងួកស្ងឹង ទាំងពីរប្រាណ ។

បន្តិចក្រោយមក ខ្ញុំភ្ញាក់ដឹងខ្លួនម្តង ហើយបើកភ្នែកព្រឹមៗសម្លឹងទៅ រថាដែលកំពុងយន់ក្នុងដំណេក ។ មិនដឹងនឹកឃើញយ៉ាងម៉េចខ្ញុំស្រាប់តែប្រៀបធៀបនាងទៅនឹងខ្លាញីមួយដ៏សាហាវ ។ ខ្ញុំសំគាល់ឃើញសញ្ញាមួយដែលមិនធម្មតា ដែលឃោរឃៅ ។ ខ្ញុំលូកដៃទៅឱបក្រសោបនាងទៀត ពេលនោះនាងភ្ញាក់ខ្លួនក្រញូងឡើង មើលនាយមើលអាយដោយភ្នែកឆ្លេឆ្លា ។

-រថា ! ... រថា ! .. គឺបងទេអូន ... គេងឱ្យស្ងៀមទៅ នាងសម្លឹង មើលមុខខ្ញុំ ដោយសេចក្តីងឿងឆ្ងល់ រួចនាងញញឹមពព្រាយឡើងៈ

-បងពិជិតទេឬ ... សូមបងអត់ទោសឱ្យអូនផង ... អូននៅភ័យ ណាស់អំពីគ្រោះថ្នាក់នៅពេលថ្មីៗនោះ ។ ថាហើយរថាស្រវាឱបខ្ញុំ ... ។

## ភាពស្ងួតស្ងន់ក្នុងវង្គសង្សារ

ខ្ញុំលក់ស្លុងផុតខ្លួនទៅក្នុងស្រុកងងឹតមួយ ដែលមានលំនាំហាក់ដូចជា ជ្រោះអន្ធការក្រៃលែណាជ្រៅ ។ លុះខ្ញុំបើកភ្នែកឡើងម្តងទៀត ខ្ញុំហាក់ដូចជាដឹងថា ខ្ញុំអស់កម្លាំងពន់ប្រមាណ ។ ខ្ញុំមានសេចក្តីងឿងឆ្ងល់ជាខ្លាំងដោយឃើញ រូបខ្ញុំមកស្ថិតនៅមន្ទីរពេទ្យទៅវិញ ហើយដោយឃើញម្តាយខ្ញុំយំសោកសង្រេង សម្រក់ទឹកភ្នែករហាមសម្លឹងមើលមកខ្ញុំភ្លឹសៗហាក់ដូចខ្ញុំជាសាកសព ។ ចំណែកឪពុកខ្ញុំលុះឃើញខ្ញុំបើកភ្នែកព្រឹមៗ គាត់ងាកចេញយ៉ាងរហ័សមានលំនាំដូច ជាភ័យខ្លាចខ្ញុំយ៉ាងសម្បើម។ ម្តាយខ្ញុំទ្រាំយូរពុំបានក៏ស្រាប់តែទ្រហោយំខ្សឹកខ្សួលអួលដើមកជាខ្លាំង គាត់ស្ទុះមកឱបខ្ញុំទាំងអណ្តឺតអណ្តក់ ។ ខ្ញុំភ័ន្តភាំងស្រឡាំងកាំង "តើមានរឿងអីអញ្ចេះ ? "។ ខ្ញុំកម្រើកខ្លួនបានបន្តិចស្រាប់តែដឹងថា សាច់មួយដុំនៅកៀនគ្រលៀនឈឺផ្សារឆៀបក្រហាយជាខ្លាំង ។ ខ្ញុំរឹតតែឆ្ងល់ ឡើងទៀត "តើខ្ញុំមានកើតអីនៅគៀនគ្រលៀន ? ។ រំពេចនោះនោះអនុស្សាវរីយ៍នៃនាងរថា ស្រីអាក្រាតដ៏មានសោភ័ណអស្ចារ្យលេចឡើងធ្លោក្នុងខួរក្បាលខ្ញុំ ។ ខ្ញុំនឹងព្រួចសង្ស័យ " មានរឿងអពមង្គលអីមួយកើតលើខ្លួនអញទេដឹង? "
។ ជាបន្ទាប់គ្នា ខ្ញុំលូតដៃស្ទាបកើ្តភេទខ្ញុំមើល បេះដូងខ្ញុំក៏ចាប់ផ្តើមវាយរន្ថើនចង់រហាកដើមទ្រូងម្ចាស់ថ្លៃអើយ ! យ៉ាងម៉េចអញ្ចេះ ម្តេចក៏មានកំណាត់ស្បៃ រុំនៅជុំវិញអញ្ចឹង ...?

-ម៉ាក់ (ខ្ញុំស្រែកឧទានខ្លាំង) ខ្ញុំកើតអីហ្នឹងម៉ាក់ ??

-កូនម៉ាក់ ! ខំទប់ចិត្តបន្តិចទៅកូន ! ខំតាំងចិត្តឱ្យស្ងប់ស្ងៀមណាកូន ...

-ម៉ាក់និយាយបន្តិចមើល ខ្ញុំកើតអីម៉ាក់ (ខ្ញុំស្រែកពេញទំហឹង )

-អាពិជិត (សម្លេងឪពុកខ្ញុំ) ឯងខំតាំងចិត្តឱ្យក្លាហានឡើងកូន ! ឯង ជាកូនប្រុស .. (ឪពុកខ្ញុំនិយាយទៀតលែងកើត ) ។

ខ្ញុំស្ទាបពិនិត្យលិង្គខ្ញុំច្បាស់ណាស់ ... លុះដឹងថាសាច់ដុំនេះត្រូវគេកាត់បាត់ទៅហើយ ខ្ញុំក៏វង្វេងលែងស្គាល់ទិសតំបន់ ។ ខ្ញុំងើបឈរឡើងក្រញាង ដូចត្រូវចរន្តអគ្គីសនីចូលមកជ្រួតជ្រាបតាមរសៃក្នុងខ្លួនដូច្នោះ ។

ប៉ា និងម៉ាក់ខ្ញុំ ស្ទុះស្រមកទប់ខ្លួនខ្ញុំឱ្យដេកទៅវិញប៉ុន្តែទប់ពុំឈ្នះ ។ ម្តាយខ្ញុំអង្វរថា :

-គេងសិនទៅកូន កុំខំងើបធ្វើអ្វី ។

ខ្ញុំប្រានអ្នកមានគុនទាំងពីរខ្ទាតត្រឡប់ត្រឡិនពេលនោះមានគិលា នុបដ្ឋាយិកាពីរនាក់ស្ទុះមករកចាប់ខ្ញុំ ។ ខ្ញុំកន្ត្រាក់បានដបទឹក Vichy ហើយ លើកសំញែងយ៉ាងសាហាវ ។

-អាណាចូលមកជិតអញៗ វាយបំបែកក្បាលខានចាស់ឥឡូវ !

ខ្ញុំស្រែកដង្ហោយដូចឆ្កែដែលលូរកម្ចាស់វា ។

-ម៉ាក់ ! នរណាក្រៀវខ្ញុំដូច្នោះ នរណាធ្វើខ្ញុំឱ្យកំបុតអញ្ចឹង, មីស្រីហ្មង ឬ ? មីរថាហ្មងឬ ? ហ៎ា ? ធ្វើម្តេចខ្ញុំនឹងរស់នៅតទៅទៀតបាន ?... បាត់ឆែង ដូចជាជ្រុលពេក ... ខ្ញុំមិនព្រមជឿទេលោកគ្រូពេទ្យ C'est pas vrai hein ? វានៅកន្លែងដដែលទេ ... វាអត់ទៅណាទេ ។ បាត់ម៉េចកើត បើវាទើបនៅហ្នឹង ថ្មីៗ ...

ដោយវង្វេងស្មារតីស្លុង ខ្ញុំក៏រត់សំដៅតម្រង់ទៅជញ្ជាំងបោកក្បាល នឹងថ្មលាន់សូរផែស ! ។ តាំងពីថ្ងៃនោះមកគេយកខ្ញុំទៅថែជំងឺនៅពេទ្យឆ្កួតអស់រវាងបីឆ្នាំ ទើបខ្ញុំមានសតិនឹងឡើងវិញបានបន្តិច ។ ប៉ុន្តែបើខ្ញុំឆ្កួតរហូតទៅដូចស្រួលជាង ... ព្រោះមនុស្សឆ្កួតបើវាអស់អីរលីងហើយ វានៅសល់គំនឹត មួយថាវាមិនឆ្កួតតែដល់ខ្ញុំជាទៅវិញ ខ្ញុំគ្រាន់តែដឹងថា ខ្លួនឯងឆ្កួតប៉ុណ្ណោះ ។

ក្រោយមកខ្ញុំបានដឹងថា រថា អតីតសិស្សវិទ្យាល័យនៅកំពត ជាស្រីវិកលចរិកម្នាក់, ប្តីនាងត្រូវគូសត្រូវវាសំឡេះចោល ហើយត្រូវគេវះយកពងទៅញាត់ក្នុងមាត់ ។ រថាដែលស្រឡាញ់ប្តីនាងណាស់ លុះឃើញសពប្តីនាងក្នុង សភាពអាក្រក់អាក្រីដូច្នោះពេកនាងក៏ខូចសតិទៅជាឆ្កួតលីលារត់បាត់ពីស្រុកប៉ុន្មានថ្ងៃ ។ ទីបំផុតនាងក៏ជួបប្រទះឡានខ្ញុំនៅកណ្តាលផ្លូវ ។ ពុំដឹងថារថាចង់ សងសឹកប្តីនាងឬយ៉ាងណា ? ឬមួយនាងតក់ស្លុតខ្លាំងពេក ។ កាលឃើញលិង្គ ប្តីនាងច្រងេងច្រងាង នៅក្នុងមាត់បណ្តាលឱ្យនាងគុំ, នៅពេលរួមសង្វាសជាមួយខ្ញុំ ។ ប៉ងកាត់ផ្តាច់លិង្គរបស់ខ្ញុំ ឱ្យដូចលិង្គរបស់ប្តីនាងដែរ ? ខ្ញុំមិនអាចសន្និដ្ឋានបានថាយ៉ាងណាៗសោះ ។ ខ្ញុំគ្រាន់តែដឹងតាមពាក្យគេថាកាលរថា បានកាត់សាច់ដុំខ្ញុំក្តាប់នៅដៃហើយ នាងរត់ទាំងអាក្រាតចេញទៅក្រៅ ។ ហោកញ្ច្រៀវផ្អើលគេឯងនៅសណ្ឋាគារ ។ ខ្ញុំឆ្ងល់ណាស់ តើនាងបានអីយកមកកាត់ ... ហើយម្តេចបានជាខ្ញុំមិនដឹងខ្លួនសោះ ?... តើនាងបានធ្វើអ្វីខ្លះ ? ត្រង់កន្លែងនេះ ខ្ញុំប្រហែលអត់ដឹងរហូតមើលទៅ ។

ខ្ញុំចេញពីពេទ្យឆ្កួតជិតពីរឆ្នាំមកហើយ ខ្ញុំខំប្រឹងឱ្យបានរស់នៅដូចគេឯង តែមិនសម្រេចសោះ ។ ចម្រៀង ឬសម្លេងកំបុតវាចេះតែរណ្តំផ្ទួនៗ ខ្សៀវខ្វាក្នុងខួរក្បាលខ្ញុំ ។ គ្រួសារគេខំយកចិត្តថ្លើមខ្ញុំណាស់ ឪពុកម្តាយ មាមីងបង ប្អូនខ្ញុំទាំងអស់, ប៉ុន្តែខ្ញុំរស់នៅដូចជាសត្វគីង្គក់ ឬដូចជាសត្វក្តាមក្នុងចំណោមអ្នកទាំងនោះ ។ ខ្ញុំមិនដឹងចង់ឱ្យអ្នកណាព្រួយចិត្តឬអាណិតខ្លួនខ្ញុំឡើយ ។ ខ្ញុំមិនត្រូវការទេ សេចក្តីអាណិត តែនរណាត្អូញត្អែរថាអាណិតវាសនាខ្ញុំ ហើយសម្លឹងខ្ញុំធ្វើភ្នែកស្លឹៗខ្ញុំចង់ច្របាច់កសម្លាប់ភ្លាម ។

មានតែមធ្យោបាយមួយ ដែលបានធ្វើឱ្យខ្ញុំធូរទ្រូងបន្តិច ។ ខ្ញុំបាន ទិញសារិកាមួយមកបង្ហាត់ ឱ្យចេះនិយាយយ៉ាងស្ទាត់។ ជួនកាលខ្ញុំដេកស្តាប់វានិយាយពេញមួយថ្ងៃ , "ស៊ីអង់ខ្វយ ? អាកំបុតអ្ហែងស៊ីត្រីខទេ ? ហាំ ! ហាំ ! ហាំ! ៗៗ អាកំបុត ... កុំលេងរន្ធឆ្អែះ ... ខ្លាចកើតប្រមេះ ... "។ ជួនកាលវាសូត្រមេរៀនជាភាសាខ្មែរកាត់យួនផង "វែនខួច ! ប៉េស ប្តីអាន់មីនណូវវែន ឡើងផ្ទះអាន់អាសាតែអាន់វាព្រួស ! អាន់ដឹងតាងអស់ ប៊ិនអាន់ណូវស៊្មុំ រួចអាន់សួរអាវែនថា ប៉ាអាបឺ ឬមិនមែនប៉ាអាបឺ វែនថា អឺ ! អឺ ! វែនចឹអាន់សឹងបាក់កហឺយ ! វែនមីនឱ្យលួយអាន់ ! ឌូមែរអាស៊ីគែប៊ូនចឹន ។ អាកំបុត ! អាកំបុត ! ហាស់ ! ហាស់ ! ៗៗ ...

ក្រៅពីនោះនៅមានមធ្យោបាយមួយទៀត ដែលអាចសម្រាលទុក្ខ ខ្ញុំបានខ្លះៗដែរ : គឺស្រីពេស្យា ។ ជាច្រើនផងណាស់ ដែលខ្ញុំត្រូវការឥទ្ធិពល សំផឹង ដើម្បីលាងស្អំដំបៅទ្រូងខ្ញុំ ។ ខ្ញុំបានជួលឱ្យវាលាតត្រដាងនូវភាពស្មោកគ្រោករបស់វាបង្ហាញចក្ខុខ្ញុំ ។ ខ្ញុំបានសុំឱ្យវាយៈច្រហេញ បញ្ចេញប្រដាប់ប្រដា និងកំអែលស្រកេកស្រកាកនឹងស្មែងច្រូងច្រាងស្មេញស្មាញ ។ ហើយខ្ញុំខំពន្យល់ ខំ "ដេម៉ុងត្រេ" ប្រាប់ខ្លួនឯងថា អារបស់អស់ហ្នឹងជារបស់ឆ្កួតៗគ្មានអីគួរឱ្យស្តាយទេ គឺជាអណ្តូងខ្ទុះគម្លង់ដែលនៅមាត់តែមមានក្រមរស្រែង និងអង្គែសំអុយគ្រប់សព្វយ៉ាង ។

ប៉ុន្តែទុក្ខព្រួយខ្ញុំមិនព្រមរលត់សោះ !! ផុតពីពេលទាំងនេះទៅទុក្ខក្រៀមក្រំ និងការសុបសៅក៏លោតហក់មកវិញមានទំហំប្រហែល ឬក៏លើសពីដើមទៅទៀត ។ ខ្ញុំខំពន្លិចរឿងអភ័ព្វរបស់ខ្ញុំនៅក្នុងសុរា ។ ខ្ញុំផឹកច្រើនណាស់រាល់ថ្ងៃ រាល់យប់ខ្ញុំខំតោងជីវិតអស់ទាំងកម្លាំងចិត្តកម្លាំងកាយ នៅតែគ្មានបាន សម្រេចលទ្ធផលអ្វីសោះ ។ ទុក្ខព្រួយនៅតែញុំញីខ្ញុំដដែល ។ ជាពិសេសអនុស្សាវរីយ៍ចាស់ៗ ។

អនុស្សាវរីយ៍ចាស់ៗនេះ ឆ្មៀលបេះដូងខ្ញុំឱ្យស្តាយស្រណោះអាឡោះ អាល័យ ចំពោះការរួមតម្រេកជាមួយស្រីៗទាំងពួង ។ គ្មានទ្រឹស្តី ឬទស្សនអី មកទប់កំសួលចិត្តនេះបានទេ បើទោះទ្រឹស្តីដែលថែងថា "ជីវិតគ្មានខ្លឹមសារក៏ដោយ " ព្រោះថាបើឥតបានរួមដំណេកជាមួយស្រីទេ ចំពោះខ្ញុំគឺឥតន័យពីរជាន់ ។ កាលខ្ញុំនៅមានប្រដាប់ប្រដាគ្រប់គ្រាន់ ស្នេហាគ្មានសម្រស់អ្វីជាសំខាន់ ប៉ុន្មានទេ

ជូនកាលខ្ញុំឡើងជិះស្រី១ទាំងធុញទាំងថប់ទៀតផង វាគ្មានស្រួលស្រណុកឋានសួគ៌ឋានសុខអីទាល់តែសោះ ។ ស្នេហាជារឿងកំប្លែងនៃល្ខោន មនុស្សជាតិសោះ ។

ខ្ញុំដឹងយ៉ាងប្រាកដណាស់, ប៉ុន្តែពេលនោះ ដែលខ្ញុំអស់សមត្ថភាពក្នុង កិច្ចស្នេហាហើយ ខ្ញុំស្រមៃឃើញស្នេហាមានតម្លៃអស្ចារ្យ ដោយអនុស្សាវរីយ៍ ជួយក្រលែមនោសញ្ចេតនាបន្តិច១ផងខ្ញុំចេះតែឃើញថា ស្នេហាជាវត្ថុក្រអែបក្រអូនរកអ្វីប្រៀបប្រដូចពុំបាន ។ ក្រអូបលើសការពិតរយដង ។ គ្មានទ្រឹស្តីអ្វី មកទប់កិលេសឈ្នះទេពេលនេះ ។ ចិត្តវាមិនដែលឈ្នះកាយសោះឡើយ ព្រោះ ចិត្តវាកើតមកពីកាយ ។ ដូច្នេះ "ចេះមិនអាចឈ្នះចង់ជាដាច់ខាត "។ រឿងសំខាន់គឺធ្វើម្តេចឱ្យខ្ញុំបានប្រដាប់ខ្ញុំមកវិញ ។ ឱ ! លោកអើយ ខ្ញុំមហាស្រេកឃ្លានស្រី១ហើយ ។ គ្មានអ្វីវេទនាជាងអត់បានដេកជាមួយស្រី១ទេ ! ឱ ! ការចំអកនៃព្រេងវាសនាកាលបានគ្នាវាគ្មានជាណាណាស់ទេ, ប៉ុន្តែបើអត់ទៅវិញ គឺប្រកាច់ចាប់មិនឈ្នះអញ្ចឹង ។ ខ្ញុំអត់ស្រីឥឡូវហ្នឹង គឺដូចជាអត់ទឹក ហេងហាង នាកណ្តាលខ្សាច់សាហារ៉ា .. ។ បើយើងឈឺបេះដូងគ្មានទ្រូងស្រី១មកស្អំទេ គ្មានដោះស្រីមួយគូមកលុញដាក់ដើមទ្រូងយើងដោយកក់ក្តៅទេ ជំងឺយើងគឺគ្មានសង្ឃឹមថាមើលជាឡើយ ! នរណាដែលងាប់ព្រោះអភ័ព្វស្នេហាខាងផ្លូវចិត្ត amour platonique ខ្ញុំគ្មានអាណិតទេ !មនុស្សយើងដែលវេទនាពិត១មែន នេះគឺវេទនាដោយផ្លូវកាយ ។ ពេលណាដែលយើងឈឺដោយគេវាយធ្វើទារុណកម្មយើង, ពេលណាដែលយើងឃ្លានដាច់ពោះ, ពេលណាដែលយើងអត់អង្គជាតិ គឺពេលនោះហើយដែលយើងទ្រាំលែងបាន ។

.................................................

...បុរសអសុរកាយបរិយាយមកដល់កន្លែងនេះក៏ឈប់ដកដង្ហើមធំ ។ ពន្លឺស្រាង១ដេញស្បែរាត្រីឱ្យរសាត់ចេញបន្តិចម្តង១ហើយ ។ ខ្ញុំក្រឡេងមើលនាឡិកា ឃើញទ្រនិចចង្អុលម៉ោងប្រាំដប់នាទី ។ ខ្ញុំមិនដែលបានស្តាប់រឿងអី ដែលអភ័ព្វដល់ម្ល៉េះសោះ ។ ខ្ញុំបានផ្ទៀងត្រចៀក ចំហមាត់ទ្រឹងស្មារតី ជូនកាលស្រុតក្បាលជង្គង់ម្តង១ កម្លាំងចិត្តទាំងប៉ុន្មាន ត្រូវរលាយខ្យុលនៅវេលានោះ ។ សេចក្តីស្នេហានៃការផ្សងព្រេង ការចូលចិត្តគ្រោះថ្នាក់ត្រូវសាមសូន្យស្រករហួតដល់បាត់បេះដូង ។

ចំពោះខ្ញុំ សូវឱ្យស្លាប់មយូររយដង កុំឱ្យតែដាច់អង្គជាតិ ។ ខ្ញុំនឹកព្រួយ ភ័យមករឿងខ្លួនឯងមួយរំពេច ខ្ញុំនេះគឺជាចៃសំដឹងតែម្តង ហើយយើងដឹងជា រឿយ១ **ជាតិ្តតសំដឹងមានឆ្នេញច្រើនណាស់ ស្វាយ, ប្រមេះ, ឃ្លង់ ២ ល២** ចុះបើថ្ងៃណាមួយក្តិតសំដឹងវាខាំស៊ីរបស់ខ្ញុំដាច់បាត់ទៅ អី យ៉ៃ ! យ៉ៃ ! ខ្ញុំមិនចង់នឹករឿងនេះទេ !!

ជនអសុរកាយអកស្រាបង្ហើយ ហើយបោកដបផ្ទងទៅលើបង្កាន់ដៃ ស្ពាន បែកអស់ពាក់កណ្តាល ។

-ខ្ញុំបានជំរាបលោកហើយ ពេលណាខ្ញុំនិយាយចប់ ខ្ញុំត្រូវទៅជួបស្រីរបស់ខ្ញុំស្រីនោះគឺមច្ចុរាជ ។ ថ្មើរនេះប្រហែលជាគ្រួសារខ្ញុំកំពុងជ្រួលច្របល់រកខ្ញុំសម្បើមណាស់,ឯសារិកាក៏ប្រហែលនឹកអាកំបុតខ្លះដែរមើលទៅ។ ប៉ុន្តែម្តងនេះ ខ្ញុំមិនឱ្យគេរកខ្ញុំឃើញទាន់ឡើយ ។ ដូច្នេះសូមលោកអញ្ជើញទៅចុះ ... ។

ខ្ញុំយល់ជាក់ថា បុរសនេះចង់ប្រហារជីវិតខ្លួនឯងហើយ ខ្ញុំស្ទុះទៅជិត ដោយអាការៈរំភើបអាណិតខ្ញុំចង់ឃាត់គេ ខ្ញុំចង់អង្វរគេឱ្យបោះអំបែងដប មួយចំហៀងចោលទៅក្នុងទឹក ។ ប៉ុន្តែអសុរកាយយារដៃឆ្វេងតប់ច្រមុះខ្ញុំយ៉ាងខ្លាំងបណ្តាលឱ្យហូរឈាមសស្រាក់ ។

-ថយឱ្យឆ្ងាយ ! កុំមកជិតខ្ញុំឱ្យសោះ ! សុំលោកកុំសម្តែងឬកអាណិតខ្ញុំ ហ្ន៎ះ ! ខ្ញុំទ្រាំមិនបានទេ !

ខ្ញុំថយចេញពីរជំហាន ។

-ទៅ ! ទៅ ! សូមលោកអញ្ជើញទៅចុះ ! កុំអាណិតខ្ញុំឱ្យសោះ ! ខ្ញុំ ខ្ពើមណាស់ ! ( បុរសស្រែកដង្ហោយ ) សូមលោកអាណិតកុំអាណិតខ្ញុំ បើពុំ ដូច្នោះលោកគេចមិនរួចពីកណ្តាប់ដៃខ្ញុំទេ, ខ្ញុំបុកខ្វាក់ ភ្នែកហ្នា៎ , កុំបង្ខំឱ្យខ្ញុំ ប្រព្រឹត្តអំពើឧក្រិដ្ឋ ... អូ ! លោកឯងចង់បានលុយទេ ?

បុរសដកលុយមួយមូរពីហោប៉ៅ ហើយជះបាចសាចមកលើក្បាលខ្ញុំ ។

-សូមលោកយកចុះ ! ខ្ញុំក្អួត ខ្ញុំខាកលើវាអស់ចិត្តហើយអាក្រដាសមិនបានការ !

ខ្ញុំងាកដើរចេញយ៉ាងប្រញាប់ ដោយភ្លេចទាំងអូសយកអាសូឡិចទៅជាមួយផង ។ ខ្ញុំតាំងចិត្តថាមិនក្រឡេកមើល ក្រោយដាច ខាត ។ ប៉ុន្តែបានតែដប់ជំហានប៉ុណ្ណោះ ខ្ញុំក៏ងាកទៅក្រោយម្តងទៀត ។ Brrrr !! ព្រះអើយ តាំងពីកើតមក ខ្ញុំមិនដែលប្រទះឃើញ ទស្សនិយភាពអ្វីដែលអាក្រក់ ដែលធ្វើឱ្យព្រឺរន្ធត់ដល់ម្លេះទេ ។ ជនអសុរកាយលើកអំបែងដបមួយចំហៀងបុកមុខខ្លួនឯងច្រាច់ៗរយះ រយាយរួចឆ្មៀតដើមទ្រូង ទើបលោតសំដៅលឿនស្ទុយទៅក្នុងទឹក ដោយស្រែកដង្ហោយយ៉ាងវែង :

**-"លាហើយ ! អាកំបុត!!"**

ខ្ញុំលែងហ៊ានត្រឡប់ទៅយកសូឡេចវិញ, ខ្ញុំមមើរមមាយដើរលែងត្រង់ផ្លូវ ។ ឈាមច្រមុះចេះតែហូរមកវិញៗមិនចប់ ។ ខ្ញុំក្រឡេកឃើញ ក្រដាសលុយប្រាំរយមួយសន្លឹក នៅលើដៃអាវខ្ញុំ ខ្ញុំរលាស់ចេញជាប្រញាប់ ដូច វាជាសត្វឈ្លើង ឬជាជំងឺឃ្លង់ ។ ខ្ញុំស្រមៃ ឃើញមុខអសុរកាយរហែកល្មៀនសាច់ ដោយអំបែងដបដូចជាសាច់ពងទាខ ។ ខ្ញុំទៅហើយ, ក្លឹស ! ក្លឹស !! សម្លេងស្បែកជើងឈើ ! អសុរកាយមកវិញទេតើ ។ ខ្ញុំបះសក់ក្រញាងព្រឺ ស្បែកគីង្គក់ ។ ខ្ញុំក្រឡេកក្រោយយ៉ាងប្រញាប់ ! គ្មានឃើញអីសោះ ។ ខ្ញុំមិនដឹងដើរ ទៅណាទេ ! ខ្ញុំមិនដឹងដើរបានការអី ដើរធ្វើអ្វី ... ទៅមុខឬទៅក្រោយ ?? ស្រឡាញ់ការផ្សងព្រេង ស្រឡាញ់គ្រោះថ្នាក់ស្រឡាញ់ជីវិត ជ្រួលច្របល់ : ស្រឡាញ់រកក្រមរអីបើនៅទីបញ្ចប់វាគ្មានអី វាមានតែរឿងដំបៅទ្រូង ! ហា ! ហា !ក្លឹស ! ក្លឹស ! អាកំបុត វែនស៊ីត្រីខទេ ! ស្លន់ ! ស្លុត ស្លន់ ! ដូច សម្លេងស្គរក្នុង សម្បជញ្ញៈ ម៉េចអញ្ចឹង ? មិនដឹងជាកើតមកបានការអី, មនុស្ស ?

វែនខូច ! ប៉េលប្ដីអាន់មិនល្អូវ វែនឡើងអាន់ ! អាសាគែអាន់វាព្រួយ ។ ស៊ីគេស្ពាន ? ! ស៊ីគេមេឃ ? ជីវិតម្តេចក៏ដូចយល់ សប្តិអញ្ចឹង ? ហ៎ , មីកថា ក្តិតង៉ែង កាលអញឃើញគ្រហាញៗជាក្តិតមែនទែន ឬក្តិតលេងៗ! ? អាន់ដឹងតាងអស់ប៊ុនអាន់ល្អូវស៊ីុមអាន់ មិននិយាយ វែនខូច! ជីវិតជាការកំផ្លុក កំប្លែកស្មោះ ។ តស៊ូទៅទៅ ! ទៅយកអី ? ហាស់ ៗ! អាកំបុតអ្លែងលេងរន្ធឆ្អេះទេ ? ក្រចកធ្មេញ ពោះវៀនស្អុយមាត់សំញេញ ! មនុស្សកាលពីដើមជាពូជស្វាទេតើ ។ មានអាទិទេពនៅឯណា ? កាលមនុស្សមកជាមនុស្សអាទិពេទ ប្រាកដជាកើតក្រោយមនុស្ស ។ ផែនដីពិត ឬមិនពិត ប្រហែលជាគ្រឿងស្រមៃទេដឹង ? ខ្ញុំស្លន់ហើយ ខ្ញុំស្លុតហើយ មិនដឹងគិតយ៉ាងណាទេ ។ មិនដឹងធ្វើអ្វីទេ , ទៅមុខ ទៅក្រោយ ឬនៅកណ្តាលស្ទើររស់ស្ទើរងាប់អញ្ចឹង ??

"L'homme est une corde tendue entre la bête et le surhomme . une corde tendue audessus d'umabîme . Danger de le franchir danger de rester enroute . danger de regarder en arriè re-frisson et arrêt dangereux "
(Nietzsvhe- (Ainsi parlait Zarathoustra )

**មានតែធ្វើដូចគេឯង មានតែធ្វើក្អួន ! ជិះគ្នាទៅ ជាប់ គ្នាទៅ ! បន្តិចៗ ចេញកូនតូចមួយ បន្តិចៗតូចលេចក្បាលមួយ រួចស្រាប់តែតូចៗ តូចៗៗ ... រួចអាន់សួរវែនថា ប៉ាអាប៊ី ឬមិន ប៉ាអាប៊ី វែនឆ្លើយថា អឺ ! អឺ ! ...**

**-ចប់-**